អន្តរឫទី
សម្លេងខ្មែរនៅបរទេស

# រាជបំរើនិងភ្នាក់ងារ

## Courts & Courtiers

**By Milton Osborne**

**( SIHANOUK: Prince of Light, Prince of Darkness )**

ប្រែសំរួលដោយ លី-ឡៀប ★ ថ្ងៃទី១១ ធ្នូ ២០០៣

( ដោយសារអត្ថបទរបស់ស្តេចសីហនុចុះថ្ងៃ៨-១១ ធ្នូ ២០០៣ សរសេរទាក់ទង<រាជបំរើនិងភ្នាក់ងារបរទេស> ខ្ញុំសុំដកស្រង់វគ្គមួយនៅក្នុងសៀវភៅ <SIHANOUK: Prince of Light, Prince of Darkness>របស់លោក Milton OSBORNE មកបកប្រែ ដើម្បីជាវិភាគទានបន្ថែមដល់ការយល់ដឹងអំពីរឿងនេះ p-146, p-147, p-148, p-149 and p-150 ) ៖

«ជនបរទេសដ៏សំខាន់ជាងគេពីរនាក់ជាបុគ្គលិករបស់សីហនុ គឺជនជាតិបារាំងឈ្មោះ Charles Meyer និង Jean Barré ។ អ្នកទាំងពីរនេះត្រួតត្រាពិនិត្យមើលភាគច្រើន លើកអត្ថបទកាសែតនិងទស្សនាវដ្តី ដែ-លបោះពុម្ពចេញដោយរដ្ឋាភិបាលខ្មែរ ។ កាសែតប្រចាំសប្តាហ៍ពាក់ក-ណ្តាលផ្លូវការ, Réalités Cambogiennes, ត្រួតពិនិត្យមើលដោយ Barré ។ គាត់នេះនិងជនជាតិបារាំងផ្សេងទៀត នៅក្នុងក្រុមបុគ្គលិករបស់សីហនុ ជាអ្នកបង្កើតទស្សនាវដ្តី Kambuja និង Le Sangkum ដែលជាទស្សនាវដ្តីសីហនុបង្កើតឡើង ក្នុងមួយរយៈពេលគាត់កំពុងសប្បាយធ្វើកាសែតកាលពីអំឡុងឆ្នាំ១៩៦០ ។ ពួកបារាំងសរសេរសុន្ទរកថា គឺជាអ្នកសរសេរឲ្យសីហនុ និងជាអ្នកទទួលបង្គាប់បញ្ជាឲ្យព្រាងនិងកែកុនសុន្ទរកថារបស់គាត់ សំរាប់ទៅចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រពត៌មានជាផ្លូវការ (AKP) ដែលជាព្រឹត្តិប័ត្ររបស់ទីភ្នាក់ងារពត៌មានខ្មែរ ។ ពួកបារាំងទាំងនោះ ជាអ្នកបោះពុម្ពផ្សាយនូវសេចក្តីរាយការណ៍ប្រចាំថ្ងៃរបស់គាត់ ។ ពួកគេពុំមែនធ្វើខ្លួនដូចពួកបរិវារនៅជុំវិញ និងដូចដែលគេធ្លាប់បានឃើញម្តងមួយយាមនៅតាមទីកន្លែងនានានោះទេ ។ ជំនួសការប្រើពាក្យយកគាប់គួរពព្រាក់ពព្រើត ពួកគេចាត់ទុកសកម្មភាពរបស់សីហនុជាការនាំមកដ៏ធំធេងខ្លាំងណាស់ ។ កាលជំនាន់ឆ្នាំ១៩៦០ គេកម្រប្រទះឃើញសីហនុត្រូវបានគេហៅថា <ជាមនុស្សមានគតិបណ្ឌិតខ្ពស់ ផ្តល់ឱកាសដ៏ត្រឹមត្រូវដល់កម្ពុជា ធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីសន្តិភាពតាមវាសនាកំណត់ទុកឲ្យ> បែបយ៉ាងដូច្នេះណាស់ ។

ពេលឆ្នាំ១៩៦០នោះ, Charles Mayer គឺពិតជាជនជាតិបរទេសម្នាក់ដ៏សំខាន់ជាងគេទាំងអស់ នៅក្នុងក្រុមបុគ្គលិករបស់សីហនុ ។ ជនជាតិបារាំងរូបនេះ, ដែលមានអ្នកខ្លះស្គាល់ថាជាជនមានទស្សនៈឆ្វេងនិយម, ជាពិសេសពួកអាមេរិកាំង, បានជះនូវឥទ្ធិពលអាក្រក់ទៅលើសីហនុ ។ ទោះបីគេស្គាល់គាត់យ៉ាងនេះក៏ដោយ គាត់គឺជាមនុស្សមានអាថ៌កំបាំងខ្លះៗដែរ ។ កើតនៅខេត្ត Alsace, គាត់បានចាប់ផ្តើមមានការពាក់ព័ន្ធជាមួយឥណ្ឌូចិននៅទីក្រុងព្រៃនគរ, ជាកន្លែងដែលតួនាទីរបស់គាត់ជំពាក់ជំពិនជាមួយព្រឹត្តិការណ៍ចុះញ៉ម បញ្ចប់នូវការគ្រប់គ្រងរបស់បារាំង និងការឡើងក្តាប់អំណាចនៃង៉ោ-ឌិនយីម មានភាពប្រពិចស្រពិលគួរឲ្យចង់ដឹង ។ គាត់បានហាត់ហ្វឹកហ្វឺនជាអ្នកភូមិសាស្ត្រវិទូ ហើយដែលក្រោយមក ភស្តុតាងបង្ហាញឲ្យឃើញថា ក្នុងជំនាញការជាអ្នកគូរផែនទី, គាត់ក្លា-យខ្លួនជាលើកដំបូង ត្រូវគេទទួលស្គាល់ទូទៅជា<ទីប្រឹក្សា>របស់បៃ-វៀង, មេដឹកនាំនៃ បិញ-ស្វៀង នៅព្រៃនគរ, ដែលជាក្រុមស្ទើរជាទាហានទុច្ចរិត ដែលបានគ្រប់គ្រងកាន់កាប់មុខរបរដ៏ស្ដុកស្ដម្ភ ពាក់ព័ន្ធល្បែងស៊ីសងនិងស្រីពេស្យា នៅក្នុងទីក្រុងព្រៃនគរ ចាប់តាំងពីពេលចប់សង្គ្រាមលោកលើកទី២មក ។ ពេលបារាំងត្រូវទទួលបរាជ័យយ៉ាងចុកចាប់កាលពីឆ្នាំ១៩៥៤, ពួកបិញ-ស្វៀងមានអំណាចនិងមហិច្ឆិតាយ៉ាងខ្លាំងក្លាគ្រប់គ្រាន់ អាចចេញមុខទៅបែងចែកអំណាចនៅក្នុងស្រុកយួនខាងត្បូងដែលទើបផុសឡើងថ្មី ។ សួរថាតើ Meyer ចាក់ចេកចាក់ស្ករត្រូវផ្លែត្រូវដងគ្នាជាមួយនឹងក្រុមទុច្ចរិតនេះយ៉ាងដូចម្តេចនោះ គេមិនច្បាស់សោះឡើយ តែនេះជាអាពាហ៍ពិពាហ៍សំរបសំរួលគ្នាមួយ ដែលគាត់បានដឹងរួចហើយ អំពីចំណូលចិត្តរបស់ខ្លួនទៅខាងឆ្វេងនិយម ។ បើបៃ-វៀងនិងក្រុមចោលម្សៀតបានដឹងអំពីទំនោរនយោបាយទោរទន់ទៅខាងណាមួយនោះ ពួកគេមុខជាមិនរួមដៃជាមួយជនឆ្វេងនិយមរូបនេះឡើយ ។

តើ Meyer បានទទួលនូវទំនុកចិត្តពីសីហនុយ៉ាងដូចម្តេច ហើយអាចដើរតួផ្នែកសំខាន់ក្នុងការកែប្រែរូបភាពសីហនុចំពោះមុខមហាជនយ៉ាងណានោះ វាក៏ជារឿងអាថ៌កំបាំងដែរ ។ តែយ៉ាងច្បាស់ពិតប្រាកដណាស់សីហនុបានទទួលស្គាល់ Meyer ថាជាមនុស្សដ៏ឆ្លាតឆ្លំនិងមានថាមពលម្នាក់ ។ តាមមើលទៅ ការប្រុងប្រៀបទទួលយក Meyer មកធ្វើជាបុគ្គលិក គឺមានអាកប្បកិរិយាស្រដៀងគ្នា ដូចកាលសីហនុធ្វើចំពោះចៅ-សេងដូច្នោះដែរ ។ ចំពោះ Meyer ដែលសីហនុយកមកធ្វើជាបុគ្គលិកនេះ គឺជាមនុស្សម្នាក់ដុះគំនិតប្រឆាំងអាមេរិកាំងរួចទៅហើយ សូម្បីតែសីហនុមានការអល់អែកបញ្ចេញទៅរោងពុម្ពក៏ដោយ ។ នៅទីបញ្ចប់, វាមិនអាចរំលងភ្នែកសីហនុបានឡើយ ចំពោះការយក Meyer មកធ្វើជាបុគ្គលិកគាត់បានចំរើនការងារពីមនុស្សម្នាក់នេះ ដែលប្រកបដោយទេពកោស-ល្យ អាចពូតបង្វិលឲ្យចេញទៅជាកិច្ចការសំខាន់ផ្សេងៗ ។ ជាថ្មីម្តងទៀត, សូម្បីតែសីហនុបរាជ័យដោយមិនបានដឹងថា ជនដែលគាត់ទុកចិត្តប្រគល់ឲ្យឆ្លាក់ឆ្លែរូបភាពរបស់គាត់ក៏ដោយ, នៅទីបំផុត ជននេះបានក្លាយទៅជាមនុស្សខាំដៃអ្នកដែលបើកប្រាក់ខែឲ្យខ្លួនទៅវិញ ។

ទោះបីសីហនុនិង Meyer ដល់ថ្ងៃក្រោយមកមានការស្រងាកចិត្តនឹងគ្នាទៅវិញទៅមកយ៉ាងណាក៏ដោយ, ទីប្រឹក្សាជាតិបារាំងរូបនេះមានការចេញចិត្តយ៉ាងច្បាស់ពិតប្រាកដណាស់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកដែលខ្លួនគាត់បានសេពគប់ជាមួយសីហនុ ។ តួនាទីរបស់គាត់មានច្រើនកន្លែងណាស់ ៖ សរសេរសុន្ទរកថា, កែកុនសុន្ទរកថាដែលសីហនុសរ-សេរដោយខ្លួនឯង, ជួយសរសេរឲ្យកាសែតRéalités និងផ្តល់សន្និសិទកាសែតក្នុងនាមរដ្ឋាភិបាល ចំពោះពួកអ្នកកាសែតបរទេស ។ Meyer មានការទទួលខុសត្រូវលើការបោះពុម្ពសំខាន់ៗធំៗខ្លះ សរសេរអំពីរាជា-ណាចក្រ, ដែលជាជំនាញការគាត់មានយ៉ាងពេញលេញ ខាងផ្នែកគូសគំនូរផែនទី ។ គាត់តែងមានការប្រុងប្រៀបរៀបចំខ្លួនទុករួចជាស្រេច ជាអ្នកជួយណែនាំផ្លូវចំពោះជនចូលមកស្រុកខ្មែរ ដែលមានបំណងរាយការណ៍សរសេរគាំទ្រអំពីប្រទេសនេះ ។ ការទាក់ទងរបស់គាត់ទូលំទូលាយណាស់ ហើយពុំមែនមានត្រឹមតែនៅក្នុងសហគមបារាំង, ពួកមន្ត្រីខ្មែរនិងឯកជនប៉ុណ្ណោះទេ គាត់ក៏មានទំនាក់ទំនងជាមួយស្ថានទូតចិន (ប្រពន្ធរបស់គាត់ជាជនជាតិចិនហុងកុង) ព្រមទាំងពួកតំណាងយួនកុម្មុយនិស្តនៅក្នុងទីក្រុងភ្នំពេញថែមទៀតផង ។

តែទោះបីជាដូច្នេះក៏ដោយ គាត់ក៏នៅតែពិបាកប៉ាន់ស្មានអំពីការប្រើឥទ្ធិពលរបស់គាត់ទៅលើសីហនុ និងទៅលើការអនុវត្តន៍នយោបាយរប

ស់សីហនុ ។ ខ្ញុំមើលឃើញគ្មានមូលហេតុអ្វីត្រូវផ្លាស់ប្តូរនូវការថ្លឹងថ្លែងដែលខ្លួនខ្ញុំចង់ធ្វើវិភាគកាលពីមុន ទៅលើបុគ្គលដ៏គួរឲ្យចាប់ចិត្តនេះទេ ដែលថា ៖ ឥទ្ធិពលរបស់ Meyer ពុំមានការសាយភាយអ្វីទាំងអស់ ដូចដែលពួកអ្នកសង្កេតការណ៍ខ្លះបានគិត និងប្រហែលមានការសមសួនជាងការដែលគេយល់ឃើញ ។ គួរបញ្ជាក់ថា វាគ្មានអ្វីត្រូវមន្ទិលសង្ស័យសោះឡើយ អំពីគាត់ជាមនុស្សដ៏សំខាន់ម្នាក់ ដែលបានធ្វើឲ្យស្តេចសីហនុអស់ជំនឿទៅលើសហរដ្ឋអាមេរិក រួចហើយត្រូវជឿយ៉ាងពិតប្រាកដផងដែរថា គ្មានជនបរទេសផ្សេងដទៃទៀតណា ដែលមានឱកាសស្មើក្បែរទៅនឹង Meyer អំពីការកាច់ចង្កូចសីហនុ ឆ្ពោះទៅរកជំហរប្រឬចិននៅក្នុងនយោបាយការបរទេស ព្រមទាំងបន្តដឹកលំជំកើងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសបារាំង ឲ្យស្ថិតនៅដដែលបាននោះឡើយ ។

មានជនបរទេសម្នាក់ទៀតតែមួយគត់ ដែលអាចជិតស្មើគ្នាទៅនឹងតួនាទីរបស់ Meyer ក្នុងឋានៈជាទីប្រឹក្សារបស់សីហនុ គឺ Jean Barré, ចាងហ្វាងកាសែត Réalités Cambodgiennes ។ ជនជាតិបារាំងទាំងពីរនាក់នេះ ក្រៅអំពីមានគំនិតឆ្វេងនិយមដូចគ្នា គេមានអ្វីផ្សេងដូចគ្នាតិចតួចណាស់ ។ Meyer, យ៉ាងហោចណាស់ កាលពីអំឡុងដើមឆ្នាំ១៩៦០ គាត់នេះកម្របង្ហាញមុខឲ្យគេឃើញ នៅក្នុងឱកាសទទួលភ្ញៀវអ្នកការទូតណាស់ ។ គាត់មានរូបរាងប្រហែលនឹងតាបស- ដែលអ្នកកាសែតអង់គ្លេស Dennis Bloodworth ប្រៀបប្រដូចទៅនឹង Molotov កាលនៅពីក្មេង ពាក់វែនតាមូល សក់ក្បាលសំពោងទៅលើមិនដឹងនិយាយប្រាប់ថាយ៉ាងដូចម្តេច និងមានមុខជ្រុង ។ ការរស់នៅក្នុងតំបន់ក្តៅយូរឆ្នាំ ធ្វើឲ្យគាត់មានរូបរាងកាយល្អ ។ ចំណែក Jean Barré វិញ ខុសគ្នាឆ្ងាយណាស់ ។ កាលពីឆ្នាំ១៩៦០, គាត់នេះចុកខ្លាញ់រួចទៅហើយ ។ អំពីរឿងមុខម្ហូបឆ្ងាញ់ មានម្តងគាត់រហូតដល់ទៅនិយាយឆ្លើយឆ្លងគ្នាជាសាធារណៈជាមួយសីហនុ នូវម៉ាកប៉ាតេថ្លើមក្រងានពិសេសណាដែលឆ្ងាញ់ជាងគេថែមទៀតផង ។ Barré គឺជាភ្ញៀវប្រចាំពិធីលៀងភោជនាហារផ្លូវការនានា និងមានទម្លាប់ចូលភោជនិយដ្ឋានល្អៗនៅភ្នំពេញ ។ ពេលចេញទៅក្រៅផ្ទះ គាត់តែងបណ្តើរប្រុសក្មេងខ្មែរ ដែលគាត់គ្មានខ្វល់អំពល់អ្វីទាំងអស់ នៅក្នុងទីក្រុងមួយដែលបញ្ហាខាងផ្លូវភេទត្រូវគេប្រកែប្រកាន់យ៉ាងខ្លាំង ដើម្បីលាក់បំពួននូវចំណូលស្នេហ៍ជាមួយប្រុសៗដូចគ្នារបស់គាត់សោះឡើយ ។ ក្លិនអាស្រូវផ្សេងទៀត ក៏មានជាប់នៅជាមួយខ្លួនគាត់ដែរ ។ គេនិយាយថា គាត់ធ្លាប់បានគាំទ្ររបប Vichy កាលពីក្មេង និងគឺដោយសារមកពីបញ្ហានេះឯងហើយ ទើបគាត់ពុំអាចវិលត្រឡប់ចូលទៅស្រុកបារាំងវិញបាន ។

ក្នុងឋានៈជាចាងហ្វាងកាសែតពាក់កណ្តាលផ្លូវការរបស់ប្រទេស, Barré មើលទៅសីហនុដូចគ្នានឹង Charles Meyer ដែរ តែពួកអ្នកសង្កេតការណ៍ដែលមានខួរក្បាលភាគច្រើននៅភ្នំពេញ គេជឿថាគាត់នេះបានបញ្ចូលឥទ្ធិពលទៅលើសីហនុ យ៉ាងច្រើនតាមដែលអាចធ្វើទៅបានដូចគ្នានឹងដៃគូរបស់ខ្លួន ។ គាត់ពេញចិត្តបំរើសីហនុខ្លាំងណាស់, ទោះបីគាត់មានរាងកាយមិនល្អយ៉ាងនេះក៏ដោយ តែគាត់តែងតែប្រុងប្រៀបខ្លួនជានិច្ច ដូចគ្នាទៅនឹងMeyerដែរ សំរួចសម្លេងប្រឆាំងអាមេរិកាំង ក្នុងពេលសរសេរព្រាងឲ្យសីហនុ ។ អង្គុយកៀកកិតជាប់ជាមួយសីហនុនៅពេលសន្និសិទកាសែត, Barré មានភារៈអាចយល់ដឹងភ្លាម ថាសីហនុចង់និយាយអំពីអ្វី... គ្រាន់តែសីហនុស្ទាក់ស្ទើរនៅក្នុងការឆ្លើយ ហើយងាមុខទៅរក Barré, គាត់នេះបំពេញគំនិតឲ្យភ្លាម ។

Meyer និង Barré គឺជាមនុស្សដ៏សំខាន់ជាងគេទាំងអស់ ដែលធ្វើការឲ្យសីហនុ និងថែរក្សាម៉ាស៊ីនឃោសនារបស់សីហនុឲ្យដើររហូត ។ ជនក្រៅពីនេះ ដែលមានតួនាទីសំខាន់ដែរមានរួម Donald Lancaster ជាលេខាភាសាអង់គ្លេសរបស់សីហនុ និងអតីតមន្ត្រីក្រសួងការបរទេសអង់គ្លេសម្នាក់ទៀត ព្រមទាំងអ្នកកាសែតបារាំង Pierre Fuchs និង Bernard Hamel ។

❑

«ជាសរុបទៅ <ពួកបរិពារសីហនុ> បានដើរតួក្នុងផ្នែករបស់គេ ដើម្បីបំភ័ន្តនូវការពិតអំពីស្រុកខ្មែរ ចំពោះភ្នែកពួកអ្នកសង្កេតការណ៍បរទេសនានា ក្រៅអំពីភ្នែករបស់ប្រជាពលរដ្ឋខ្មែរ ។ ដែលសំខាន់ជាងគេ... សំរាប់រយៈព្រឹត្តិការណ៍ក្រោយមក, ពួកអ្នកដែលជិតស្និទ្ធជាមួយសីហនុទាំងអស់នេះ ទាំងនៅក្នុងកិច្ចការងាររបស់គាត់ និងទាំងនៅក្នុងការបង្វែងដានសព្វបែបយ៉ាងនោះ, តែងតែមានគំនិតលាក់បំបាំងពីសីហនុ នូវរឿងរ៉ាវជាច្រើនដែលមិនសូវមានគេដឹងឮ និងរឿងគួរបារម្ភពិតៗនៃរាជាណាចក្រ ។ ជាមួយក្រុមដ៏ជិតស្និទ្ធទាំងអស់នេះ, សីហនុបានបែរខ្នងដាក់ហេតុការណ៍ស្រុក ដែលគួរណាស់តែត្រូវខ្វល់អំពល់ ។ ពួកទីប្រឹក្សាដ៏ជិតដិតដែលសីហនុផ្តោតក្តីរំពឹងទៅលើនិងឲ្យចាត់ចែងធ្វើកិច្ចការរដ្ឋក្នុងនាមគាត់ កម្រហ៊ាននិយាយប្រឆាំងសីហនុ និងហ៊ានព្រមានដល់សីហនុ អំពីការពិបាក ឬបញ្ហាកើតមានឡើងចំពោះនយោបាយ ដែលសីហនុបានបង្កណាស់ ។ ក្នុងឋានៈជាអ្នកតំណាងសញ្ជាតិបរទេស ដែលដើរតាមសីហនុតត្រុក ពីពិធីមួយទៅពីធីមួយ, វត្តមានរបស់ពួកគេគឺគ្រាន់តែសំរាប់បំពេញចិត្តសីហនុប៉ុណ្ណោះ ទោះបីរឿងនោះសំខាន់ជាងស្រុកខ្មែរធំប៉ុនណាក៏ដោយ ។ ពេលពួកគេជួបសវនាការជាមួយសីហនុ ៗពេញចិត្តស្តាប់តែនរណាដែលសរសើរពីនយោបាយរបស់គាត់ ហើយមានប្រតិកម្មប្រឆាំងតបតចំពោះការផ្តល់យោបល់ទាំងឡាយណា ដែលត្រូវការធ្វើការកែសំរួល ។

នៅពេលនោះពួកអ្នកជំនាញការបារាំង, ពួកលេខារបស់គាត់អស់នេះ ក៏សរសេរបញ្ជោរលើកជើង តាមដូចដែលសីហនុសព្វព្រះទ័យចង់ គឺបញ្ចេញនូវទស្សនៈ<ប្រឆាំងចក្រពត្តិនិយម> ដូចដែលពួកគេចង់បានដូចគ្នាដែរ ។ ច្រើនឆ្នាំក្រោយមក, សីហនុបានរៀបរាប់អំពីបរាជ័យរបស់ខ្លួន ដោយទទួលស្គាល់ រហូតដល់ទៅគំនិតដ៏ខ្លីមៗ ដែលហក់បកត្រឡប់មកប្រឆាំងនឹងគាត់វិញ ថាជា<ការឆោតល្ងង់ដែលមិនអាចអត់ឱនឲ្យបាន» ។ តាមពិតទៅ គាត់ហួសពីគ្មានដឹងខ្យល់អ្វីទៅទៀត ។ គាត់គឺជាជនរងគ្រោះចំពោះភាពត្រៀមខ្លួនរបស់គាត់ ដែលមិនខ្វល់អំពល់ចំពោះការពិត ផ្តោតអារម្មណ៍តែទៅលើការស្រមើស្រមៃដ៏ល្ងង់ខ្លៅឥតប្រយោជន៍ និងទំយើស៊ីជោរឆ្អែតនឹងខ្លួនឯង ដោយគ្មានការថ្លឹងថ្លែងប្រមើមើលមកខ្លួនឯងនិងប្រទេសជាតិរបស់ខ្លួនសោះឡើយ ។ ដរាបណា ការកំហែងនៅក្នុងស្រុក និងបរទេសទៅលើមុខតំណែងរបស់គាត់ត្រូវទប់ស្កាត់បាន ដូចកាលពីអំឡុងមុនឆ្នាំ៦០, ចរិតរបស់សីហនុគ្មានខ្វល់អំពល់អ្វីទាំងអស់ ។ តែនេះក៏ពុំមែនជាករណីជានិច្ចនោះឡើយ » ។

( <u>កកន</u> ៖ នរណាក៏ដោយដែលសរសេរពីការពិតរបស់ស្តេចសីហនុ ៗមិនចូលចិត្តទេ ។ ស្តេចសីហនុស្អប់លោក Melton Osborne ដូចសំរាមសូម្បីតែសៀវភៅនេះក៏គ្មានលក់នៅក្នុងស្រុកខ្មែរដែរ ។ ក្នុងមួយជីវិតរបស់ស្តេចសីហនុ ៗចូលចិត្តតែ<ពួកឆ្វេងនិយម>ប៉ុណ្ណោះ ហើយក៏រស់នៅស៊ីចុកបុកទំពារជាមួយពួកនេះផងដែរ ។ សូមអញ្ជើញសង្កេតមើលចុះ ស្តេចសីហនុគ្មានទុកចិត្តនរណាក្រៅពួកកុម្មុយនិស្តទេ សូម្បីតែ<អង្គរក្ស>នៅក្នុងស្រុករបស់ខ្លួនឯងសោះ ក៏ស្តេចសីហនុជ្រើសរើសយកជនជាតិកូរ៉េខាងជើងជំនួសអង្គរក្សជាជនជាតិខ្មែរ ។ ស្តេចសីហនុឲ្យតម្លៃទៅលើបរទេស ជាងជាតិសាសន៍ខ្មែរ ។ សូម្បីតែប្រធានាធិបតីកូរ៉េខាងជើងឲ្យអាវមួយកំប្លែ ក៏ខំប្រឹងត្រហេបត្រហបអួតប្រាប់ពិភពលោកខ្លាយៗដោយគ្មានការអៀនខ្មាស់សោះឡើយ ) ។

សម្លេងខ្មែរនៅបរទេស

# ជួយគេនិងចូលគេ មានន័យខុសគ្នា!!

ដោយ លី-ឌៀប ★ ថ្ងៃទី១២ មករា ២០០៨

★ ក្នុងជំពូកទី២១, Niccolò Machiavelli សរសេរយ៉ាងដូច្នេះថា ៖

« A prince is also respected when he is a true friend and a true enemy; that is, when he declares himself on the side of one prince against another without any reservation. Such a policy will always be more useful than that of neutrality; for if two powerful neighbours of your come blows, they will be of the type that, when one has emerged victorious, you will either have cause to fear the victor or you will not. In either of these two cases, it will always be more useful for you to declare youself and fight an open war; for, in the first case, if you do not declare your intentions, you will always be the prey of the victor to the delight and satisfaction of the vanquished, and you will have no reason why anyone would come to your assistance; because whoever wins does not want reluctant allies who would not assist him in times of adversity; and whoever loses will not give you refuge since you were unwilling to run the risk of coming to his aid » ។

« អង្គម្ចាស់អាចធ្វើឲ្យគេគោរពថែមទៀត នៅក្នុងពេលព្រះអង្គធ្វើខ្លួនជាមិត្ត និងធ្វើជាសត្រូវយ៉ាងពិតប្រាកដ ។ មានន័យថា ពេលអង្គម្ចាស់ប្រកាសខ្លួនឯង នៅខាងព្រះអង្គម្ចាស់ម្នាក់ ធ្វើការប្រឆាំងនឹងព្រះអង្គម្ចាស់ម្នាក់ទៀតដោយគ្មានការអល់អែកអ្វីទាំងអស់ ។ វិធីបែបនេះ ត្រូវតែល្អប្រសើរជានិច្ច ជាងស្ថិតនៅជាកណ្ដាល ។ ព្រោះបើប្រទេសជិតខាងខ្លាំងៗទាំងពីរនោះផ្ទុះសង្គ្រាមជាមួយគ្នា គេនឹងមានលក្ខណៈយ៉ាងដូច្នេះ គឺថានៅពេលខាងមួយណាឈ្នះ អង្គម្ចាស់នឹងត្រូវខ្លបខ្លាចអ្នកឈ្នះ ឬមួយអង្គម្ចាស់មិនខ្លាច ។ នៅក្នុងករណីទាំងពីរយ៉ាងនេះ វាជាការល្អប្រសើរជានិច្ចសំរាប់អង្គម្ចាស់ គឺត្រូវប្រកាសខ្លួនឯង និងចេញច្បាំងយ៉ាងចេញមុខ ។ ចំពោះករណីទីមួយ, បើអង្គម្ចាស់មិនព្រមប្រកាសឲ្យគេដឹងពីចេតនារបស់ទ្រង់ទេ អង្គម្ចាស់មុខជាត្រូវទទួលរងគ្រោះក្លាយជាចំណីនៃប្រទេសឈ្នះសង្គ្រាមពុំខាន រួចហើយអង្គម្ចាស់ក៏គ្មានហេតុផលអ្វីគិតថា គ្មាននរណាម្នាក់គេអើតមុខមកជួយអង្គម្ចាស់ឡើយ ពីព្រោះប្រទេសដែលឈ្នះនោះ គេមុខជាស្ទាក់ស្ទើរមិនចង់ចងសម្ពន្ធមិត្តនឹងអ្នកណា ដែលមិនជួយគេនៅក្នុងគ្រាពួកគេមានគ្រោះកាចកើតឡើងនោះឡើយ, ហើយចំណែកប្រទេសដែលចាញ់វិញ គេក៏មិនរាប់អានអង្គម្ចាស់ដែរ ចាប់តាំងពីអង្គម្ចាស់មិនព្រមប្រថុយប្រថានចេញមុខទៅជួយពួកគេ » ។

ស្ដេចសីហនុគិតថា ៖ ការផ្ដល់ទឹកដីខ្មែរនៅតាមបណ្ដោយព្រំដែនខ្មែរទិសខាងកើត ដល់ពួកយួនយៀកកុង-យៀកណាមខាងជើង តាំងមូលដ្ឋានធ្វើជាជំរកទ័ពទីងដើម្បីច្បាំងជាមួយយួនរដ្ឋការខាងត្បូងនិងកម្លាំងទ័ពអាមេរិកាំង គឺជាការជួយប្រទេសជិតខាង ។ តែតាមការពិតវិញ គឺព្រះអង្គទៅចុះចូលជាមួយពួកយៀកកុង-យៀកណាមខាងជើងទៅវិញសោះ ។

ពាក្យ<ជួយ>មានន័យថា ៖ ខ្លួនយើងមានកម្លាំងកំហែងមាំមួន ស្ម័គ្រទៅបន្ថែម ឬរួមកម្លាំងជាមួយគេ ។ រីឯពាក្យថា<ចូល>វិញ មានន័យខ្លួនឯងទន់ខ្សោយ សុំទៅវាយអែបស៊ីអុកជាមួយគេ... បើគេឈ្នះសង្គ្រាម... អញក៏ឈ្នះត្រសងជាមួយនឹងគេដែរ (!!)

ដល់ដូច្នេះទៅ... វាខុសគ្នាពីទ្រឹស្ដីរបស់ Machiavelli ទាំងស្រុង ។ អ្នកលើកស្លកទៅចុះចូលជាមួយគេ គឺទៅក្នុងឋានៈជា<ខ្ញុំបំរើគេ> ស្រេចតែគេប្រើប្រាស់ហួចុកទៅតាមចំណង់ចំណូលចិត្តរបស់គេ ។ ជនជំពូកនេះគ្មានកិត្តិយសទេ មិនខុសគ្នាជា<ឆ្កែបំរើ>របស់គេ ដែលនៅទីបំផុតត្រូវចាញ់បោកគេទទឹកស្លាបជោគនោះឡើយ ។ សព្វថ្ងៃនេះ ស្ដេចសីហនុមិនត្រឹមតែធ្វើជា <កញ្ជះបរទេស> ប៉ុណ្ណោះទេ ព្រះអង្គពេញចិត្តធ្វើជា <កញ្ជះនៃពួកអាយ៉ងបរទេស>ថែមទៀត ។ សូមអញ្ជើញស្ដាប់សំដីរបស់ស្ដេចសីហនុ ដែលយើងដកស្រង់ចេញពីសៀវភៅក្រោមចំណងជើងថា «សង្គ្រាមនិងក្ដីសង្ឃឹម» (War & Hope) ត្រង់វគ្គ <សង្គ្រាមខុសប្រក្រតីមួយ, ឆ្នាំ១៩៧០-១៩៧៥> ( An "Extraordinary" War, 1970-1975) p-16-17- 18 and 19 មកធ្វើការបកប្រែក្រៅផ្លូវការដូចតទៅនេះ ៖

«ក្នុងរយៈពេលប្រាំឆ្នាំនៃការប្រយុទ្ធរួមរបស់យើង ប្រឆាំងចក្រពត្តិនិយមអាមេរិកាំង, កងទ័ពរបស់ប្រធានាធិបតីក្រុងសៃហ្គុងង្វៀង-វ៉ាន់ធីវនិង<សាធារណរដ្ឋ>លន់-នល់, ខ្ញុំមានកិត្តិយសបានធ្វើទស្សនកិច្ចទៅទីក្រុងហាណូយជាង១០ដង ឬច្រើនលើសពីនេះ ។ នៅរាល់លើក ខ្ញុំស្នាក់នៅក្នុងក្រុងហាណូយ ខ្ញុំមានឱកាសជួបនិយាយគ្នាយ៉ាងវែង ហើយខ្ញុំសូមសារភាពដោយស្មោះថា គឺជួបជាមួយពួកមេដឹកនាំដ៏សំខាន់ៗនៃវៀតណាមខាងជើងជាពិសេសផាំម-យ៉ាំងដុង, យ៉-ង្វៀងយ៉ាប់, ទ្រុង-ជីញ ឡេ-ដួាន់, ង្វៀង-ឌុយទ្រីញ ហើយសូម្បីរហូតដល់ទៅប្រធានាធិបតីតុង-ឌឹកថាង ដែលជាជនដ៏មានចំណាស់ជាងគេ គួរឲ្យស្រឡាញ់ និងដ៏មានប្រាជ្ញាភ្លឺថ្លាផងដែរ ។

ខ្ញុំមានទំនុកចិត្តនិងការស្រឡាញ់រាប់អានជាមិត្តភាពជាមួយ ផាំម-យ៉ាំងដុង និងយ៉-ង្វៀងយ៉ាប់ ។ ពួកគេចូលចិត្តនាំគ្នាមកដំណាក់របស់ខ្ញុំនៅក្រុងហាណូយ ហើយនិងមកទទួលទានបាយថ្ងៃត្រង់ឬបាយល្ងាចជាមួយខ្ញុំ ។ មុននិងក្រោយពេលបាយ យើងមានការជជែកនិយាយគ្នាយ៉ាងវែងនិងគួរឲ្យចាប់អារម្មណ៍ អំពីព្រឹត្តិការណ៍បច្ចុប្បន្ននានា ជាពិសេសដំណើរច្បូល្បមដៃគ្នារបស់យើងប្រឆាំងនឹងអាមេរិកាំង ។

វាជាការពិតណាស់ ដែលថាយើងប្រើភាសាតែមួយដូចគ្នា គឺភាសាបារាំង ហើយដែលថា ពួកជនកុម្មុយនិស្ដដូចជា ដុង, យ៉ាប់, ទ្រុង-ជីញ ជាដើម... ចូលចិត្តបង្ហាញមុខខុសប្លែកគ្នាខ្លាំងណាស់ពីរបៀបដើមនៃពួកជនកុម្មុយនិស្ដជាទូទៅ ។ សូម្បីពេលពួកគេនិយាយទៅកាន់កាសែតអន្តរជាតិ, ផាំម-វ៉ាន់ដុងនិងក្រុមរបស់គាត់ ចេញបង្ហាញមុខយ៉ាងចំហនិងយ៉ាងខែងវែង មិនដូចរបៀបពួកជនកុម្មុយនិស្ដជាទូទៅ ដែលមានគំនិតបិទបាំង និងមិនព្រមនិយាយស្ដីអ្វីនោះទេ ។

យ៉-ង្វៀងយ៉ាប់, ជនអ្នកឈ្នះសង្គ្រាមដ៏ត្រចះត្រចង់នៅឌៀនបៀនភូ ជាអ្នកមានការពេញចិត្តផងដែរ ក្នុងការចាត់ចែងរៀបចំកិច្ចប្រជុំសំរាប់ខ្ញុំក្នុងពេលដែលយើងពិភាក្សាគ្នាអំពីយុទ្ធវិធីដ៏ឆ្នើម សំរាប់យកទៅអនុវត្តប្រឆាំងជាមួយសត្រូវរួម ។ កិច្ចប្រជុំការងារនេះ ធ្វើឲ្យខ្ញុំរៀនសូត្រយល់ដឹងបានច្រើនណាស់ ចាប់តាំងពីពួកគេបើកបង្ហាញឲ្យឃើញថា វៀតណាមខាងជើងស្គាល់ស្រុកខ្មែរដូចបាតដៃរបស់ពួកគេ ។ យ៉ាប់បញ្ចេញឲ្យឃើ

ញនូវផែនទីស្រាវជ្រាវយ៉ាងហ្មត់ចត់អស្ចារ្យខាងទាហាន ដោយការណែនាំខ្លួនខ្ញុំឲ្យបានស្គាល់ពួកសក្តិប្រាំៗ ជាបុគ្គលិកជំនាញការក្នុងរឿងស្រុកខ្មែរ ដែលជាអ្នកអាចចង្អុលបង្ហាញប្រាប់ខ្ញុំនៅលើផែនទី អំពីទឹកថ្លុកតូចមួយមានទឹកពេញនៅរដូវប្រាំងទាំងភ្នែកបិទជិត ។ ដល់ដូច្នេះទៅ ខ្ញុំអាចមើលឃើញយ៉ាងច្បាស់ថា យួនគ្មានទុកឱកាសត្រង់កន្លែងណាមួយ និងផ្តល់នូវគ្រោះថ្នាក់ដ៏អស្ចារ្យចំពោះសត្រូវ បើប្រសិនណាយើងជាខ្មែរត្រូវតតាំងជាមួយពួកគេ ដូចលន់-នល់បានចាប់ផ្តើមធ្វើកាលពីខែមិនាឆ្នាំ១៩៧០យ៉ាងដូច្នោះ ។

(<u>កកន</u> ៖ នៅពេលប្រជាពលរដ្ឋខ្មែរនាំគ្នាដង្ហែរស្តេចសីហនុ ចុះចេញពីតំណែងប្រមុខរដ្ឋ និងបើព្រះអង្គមិនហក់ទៅចូលដៃជាមួយសត្រូវយួនស្នូរជាតិទេ... ពួកយួនទាំងអស់នេះក៏គ្មានលេសអ្វីលោតមកផ្តិលផ្តាច់អាយុជីវិតខ្មែរនិងប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរ ស្ទើរពាយអស់ពីនគរយ៉ាងដូច្នេះដែរ ។ នេះហើយជាកំហុសយ៉ាងធ្ងន់ធ្ងររបស់ស្តេចសីហនុ ដែលសាវតាជាតិពុំអាចបំភ្លេចបានសោះឡើយ ! ) ។

«ក៏ប៉ុន្តែ តើយើងអាចកំចាត់គំនុំចាស់របស់ខ្មែរប្រឆាំងនឹង<យួន> ដូចម្តេចបានទៅ ? ។

(<u>កកន</u> ៖ ពាក្យ<យួន>នេះ កាលជំនាន់អ៊ុនតាក់ ឬកាលជំនាន់ស្តេចសីហនុស្តេចយាងចូលស្រុក ព្រះអង្គប្រកាសមិនឲ្យគេប្រើទេ ពីព្រោះព្រះអង្គទ្រង់ឈ្វេងយល់ថា គឺជាពាក្យ<ប្រកាន់ពូជសាសន៍> ។ ដល់ឮដូច្នោះលោកយ៉ាស៊ូស៊ុី-អាកាស៊ី ក៏ថាតាមស្តេចសីហនុដែរ ។ សូមបញ្ជាក់ថា ទន្ទឹមគ្នាក្នុងពេលនោះផងដែរ ស្តេចសីហនុបានប្រកាសឲ្យដឹងថា ព្រះអង្គរកមើលមិនឃើញមានជនជាតិយួនដល់ម្នាក់សោះនៅក្នុងស្រុកខ្មែរ !) ។

«សូម្បីតែពួកកុម្មុយនិស្តបួបរួមជាតិកម្ពុជា (FUNK), ពេលពួកគេត្រូវអញ្ជើញឲ្យទៅក្រុងហាណូយកាលពីឆ្នាំ១៩៧០-១៩៧១, ដែលជាដំណាក់កាលដ៏ត្រកុំត្រកាលបំផុតនៃសម្ពន្ធភាពរបស់យើងជាមួយវៀតណាមខាងជើង ពេលរៀបចំដើម្បីនិយាយនៅក្នុងផ្ទះទទួលភ្ញៀវរបស់ពួកគេនៅក្រុងហាណូយ អំពី<ពុតត្បុតរបស់យួន> និងអំពី <សេចក្តីត្រូវការរបស់ខ្មែរនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីប្រយ័ត្នប្រយែងចៀសវាងបំណងវៀតណាមខាងជើងយកប្រៀបលើយើង នៅក្រោយពេលដែលក្រឡេកមើលឃើញជាមុន នូវជ័យជំនះរួមគ្នាលើពួកចក្រពត្តិឈ្លានពាននិងជនក្បត់លន់-នល់ ។

ហើយដោយសារជញ្ជាំងមានត្រចៀក, សម្លេងខ្សឹបខ្សៀវគ្នារបស់ពួកកុម្មុយនិស្តរណសិរ្សរួបរួមជាតិកម្ពុជា ក៏បានលេចឮទៅដល់ឧត្តមសេនិយយ៉ាប់ ។ បន្តិចប៉ុណ្ណោះក្រោយមក, ទឹកមុខរបស់គាត់ឡើងក្រហមដោយកំហឹង, គាត់សំដែងនូវការតូចចិត្តរបស់គាត់ចំពោះខ្ញុំដោយពាក្យសំដីដូចតទៅនេះ ៖ «យើងវៀតណាមខាងជើង ជាកុម្មុយនិស្តពិតប្រាកដ... ជាមនុស្សប្រកាន់ពាក្យសំដី ។ យើងបានសន្យាចំពោះព្រះអង្គយ៉ាងឧឡារឹក ហើយជាលាយល័ក្ខអក្សរថា យើងត្រូវតែគោរពជានិច្ចអធិបតេយ្យភាពរបស់ព្រះអង្គ, ឯករាជភាពជាតិព្រះអង្គ, ទឹកដីរបស់ព្រះអង្គនៅក្នុងពេលសព្វថ្ងៃនេះ រួមទាំងកោះទាំងឡាយនៅក្នុងជ្រោយសមុទ្រផង ។ យើងពុំដែលបំបែកពាក្យសន្យារបស់យើងទេ ។ ភស្តុតាងដ៏អស្ចារ្យនៃការស្មោះត្រង់របស់យើងចំពោះកម្ពុជា ហើយនិងប្រមុខរដ្ឋរបស់គេ (សំដៅចំពោះខ្ញុំនាពេលនោះ) គឺការធ្វើពលិកម្មអាយុជីវិតនៃប្រជាជនវៀតណាមរាប់រយនាក់ បូជាជូនស្រុករបស់ព្រះអង្គ ។ នេះគឺជាការធ្វើឲ្យអាម៉ាស់មុខយ៉ាងធ្ងន់ធ្ងរធ្វើឡើងដោយពួកកុម្មុយនិស្តនៃរណសិរ្សរួបរួមជាតិកម្ពុជា ដោយបូកសរុបយើងទាំងអស់គ្នាទាំងមិនសមរម្យទាល់តែសោះ រាប់បញ្ចូលគ្នាជាមួយពួកចក្រពត្តិអាមេរិកាំងឈ្លានពានប្រទេសទាំងបីនៃឥណ្ឌូចិន ។



ស្តេចសីហនុ និង ង៉ៀង-ហ៊ុយថូ

សំដីប្រឆាំងយួនរបស់ពួកគេដែលធ្វើឡើងនៅហាណូយនេះ ធ្វើឲ្យយើងចុកចាប់ខ្លាំងណាស់ នៅក្នុងពេលរាល់ថ្ងៃដែលទាហានរបស់យើង ស្ថិតនៅឆ្ងាយពីភូមិកំណើតនិងពីគ្រួសារជាទីស្នេហា ត្រូវទៅធ្វើការប្រយុទ្ធនិងត្រូវស្លាប់នៅលើទឹកដីជាទីសក្ការៈនៃបងប្អូនប្រុសស្រីខ្មែរ, ស្មាទល់និងស្មាប្រឆាំងសត្រូវរួម ដើម្បីសង្គ្រោះនិងរំដោះប្រទេសរបស់ព្រះអង្គ គឺកម្ពុជា» ។

ថ្វីបើពួកគេពុំបានដឹងក៏ដោយ, ភ័ព្វសំណាងគឺកំពុងកើតមាននៅខាងលន់-នល់និងពួកអាមេរិកាំងនាពេលនោះ ។ ពួកខ្មែរក្រហមនិងយួនបានប្រែប្រួលយ៉ាងឆាប់រហ័ស ពីការផ្តោះផ្តងតាមពាក្យសំដី ទៅជាការបាញ់ប្រហារគ្នាទៅវិញទៅមក ។ សកម្មភាពខំប្រឹងប្រែងចូលរួមគ្នារបស់យើង ក៏ត្រូវទទួលលទ្ធផលខ្វិនខ្វង់ជាទម្ងន់ផងដែរ ។

នៅខែមិនាឆ្នាំ១៩៧៣, ប្រពន្ធរបស់ខ្ញុំ ម៉ូនិក ហើយនិងខ្ញុំ បានត្រូវមិត្តវៀតណាមរបស់យើង ជូនដំណើរចេញពីវៀតណាមខាងជើង ចុះទៅព្រំដែនលាវ-ខ្មែរ (រួមទាំងលោករដ្ឋទូតង៉ៀង-ធួងក្នុងនោះផង) ជិះឡានហ្ស៊ីបធ្វើនៅសូវៀត ធ្វើដំណើរតាមផ្លូវមួយនៃផ្លូវលំហូ-ជីមិញដ៏ច្រើន ។ យើងហៀបទៅដល់ស្រុកខ្មែរតទៅហើយ ទើបលោករដ្ឋទូតង៉ៀង-ធួងខ្សឹបប្រាប់ទៅម៉ូនិក (ពេលខ្ញុំឱបគ្នាជាមួយហ៊ូ-នីមនិងសុន-សេន) ដើម្បីឲ្យប្រាប់ខ្ញុំ សុំឲ្យខ្ញុំកុំនិយាយសរសើរអំពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងសុំកុំឲ្យខ្ញុំនិយាយថា ខ្ញុំសប្បាយចិត្តដោយបានចងមិត្តគ្នាយ៉ាងជិតស្និទ្ធរវាងសម្ពន្ធភាពរណសិរ្សរួបរួមជាតិកម្ពុជា ជាមួយស្រុករបស់គាត់ ។ តើព្រោះហេតុអ្វីទៅ? «ពីព្រោះមកពីសមមិត្តខ្មែរយើងមានចិត្តស្រាលឆាប់ខឹងខ្លាំងណាស់អំពីចំណុចនេះ», គាត់ពោល ។ នេះគឺជាការភ្ញាក់ផ្អើលដំបូងបង្អស់របស់ខ្ញុំ ទាក់ទងទៅនឹងទំនាក់ទំនងថ្នាក់រដ្ឋរវា

ងពួកខ្មែរក្រហម និងសមមិត្តរួមអាវុធយួនរបស់ពួកគេ ។

ក្នុងរយៈពេលឆ្នាំ១៩៧៨, ខៀវ-សំផន, ជនឡើងធ្វើជាប្រមុខរដ្ឋបន្តពីខ្ញុំ, ចូលមកនិយាយប្រាប់ខ្ញុំថា ទោះបីកំពុងស្ថិតនៅកណ្ដាលសង្គ្រាមប្រឆាំងអាមេរិកាំងយ៉ាងដូច្នេះក៏ដោយ, គណបក្សកុម្មុយនិស្តកម្ពុជានិងកងទ័ពបដិវត្តន៍មិនដែលឈប់នឹកគិតថា យួននិងកងទ័ពរបស់វាជាសត្រូវទីមួយនោះឡើយ ។ គាត់ថ្លែងបញ្ជាក់ថា ៖ «ពួកអាមេរិកាំងអាចឈ្លានរុកយើងសើៗប៉ុណ្ណោះ, តែចំណែកឯពួកយួនវិញវាលេបស្រុកយើង, វានឹងបញ្ជូនប្រជាជនរបស់វារាប់លាននាក់មកធ្វើអាណានិគមស្រុកយើង វាកាត់បន្ថយប្រជាជនខ្មែរយើង៨លាននាក់ ឲ្យមកនៅត្រឹមតែជាជនជាតិភាគតិច ៖ នេះជាទីចុងចប់នៃសញ្ជាតិរបស់យើង និងអធិបតេយ្យភាពជាតិរបស់យើង ! » (១) ។

នេះគឺជាការគ្មានមន្ទិលសង្ស័យសោះឡើយ អំពីមូលហេតុមួយដែលខ្មែរសាធារណរដ្ឋរបស់លន់-នល់ មិនរលំដួលភ្លាមៗ ។ សូម្បីតែកាសែតអាមេរិកាំង ដែលកាលក្នុងឆ្នាំ១៩៧១-១៩៧២ បានទស្សន៍ទាយទុកថា លន់-នល់នឹងត្រូវបរាជ័យក្នុងឆ្នាំ១៩៧៣នោះ ហួសចិត្តយ៉ាងខ្លាំងដោយឃើញរបបនេះមានអាយុវែង <មិនអាចពន្យល់បាន> ។ ។ មូលហេតុនៃការមានអាយុវែងគួរឲ្យភ្ញាក់ផ្អើលនេះងាយសោះ ៖ គឺមកពីពួកខ្មែរក្រហមពុំបានជាប់ដៃយ៉ាងខ្លាំងក្លាជាមួយពួកចក្រពត្តិនិយមអាមេរិកាំងទេ ។ ទិសដៅចំបងរបស់ពួកគេ គឺចង់ស្មើគ្នាជាមួយពួកសមមិត្តរួមអាវុធវៀតមិញនិងវៀតកុង... នេះបើមិននិយាយដល់ការចង់កំចាយយ៉ាងស្វិតស្វាញទៅលើពួកខ្មែរវៀតមិញព្រមទាំងកម្លាំងប្រួសីហនុ ! សង្គ្រាមដែលមានរយៈពេលចាប់ពីខែមិនាឆ្នាំ១៩៧០ រហូតដល់ខែមេសាឆ្នាំ១៩៧៥ គឺជាសង្គ្រាមខុសប្លែកធម្មតា និងខុសប្រក្រតីមួយ ។

(១) ពេលខៀវ-សំផននិយាយអំពី«ប្រជាជនខ្មែរចំនួន៨លាននាក់» គឺគាត់និយាយហួសពីការពិតទាំងស្រុង ៖ តាមពិតប្រជាជនខ្មែរទាំងអស់ នៅពេលនោះមានមិនដល់៥លាននាក់ផង ។

យោងតាមបន្ទូលរបស់ស្ដេចសីហនុខាងលើនេះ ព្រះអង្គផ្ដេកផ្ដួលជំនឿទាំងស្រុងទៅលើពួកយួនហាណូយ រួចហើយចាត់ទុកយួនហាណូយជាទ័ពមុខប្រឆាំងអាមេរិកាំង ។ ព្រះអង្គតែងលើកដម្កល់ដម្កើងពួកមេដឹកនាំយួនហាណូយ ស្មើជា<ចៅហ្វាយ>របស់ព្រះអង្គ សូម្បីតែរដ្ឋទូតយួនហាណូយដ៏តូចមួយ ក៏អាចខ្សឹបឲ្យព្រះអង្គធ្វើតាមបានដែរ ។

សំដីរបស់ខៀវ-សំផនដែលស្ដេចសីហនុបានលើកឡើង ធ្វើឲ្យយើងយល់ថា ពួកខ្មែរក្រហមទោះបីយ៉ាងណា ក៏មានគំនិតជាតិនិយមប្រសើរជាងស្ដេចសីហនុដែរ ។

នៅក្នុងសៀវភៅនេះទាំងមូល យើងប្រទះឃើញនៅក្នុងវគ្គនេះប៉ុណ្ណោះ ដែលស្ដេចសីហនុមានបន្ទូលអំពី «កម្លាំងប្រួសីហនុ» ។ កម្លាំងនេះបើតាមយើងយល់ ប្រហែលមិនសំខាន់ ឬក៏ពុំមានរូបរាងពិតប្រាកដផង ។ ពីព្រោះស្ដេចសីហនុមិនដែលមានពេលណាបានថ្លែងបញ្ជាក់ឲ្យពិតប្រាកដសោះ អំពីចំនួន, សកម្មភាព និងឈ្មោះមេទ័ពរបស់ព្រះអង្គ ។ យើងជឿថា«កម្លាំងប្រួសីហនុ»នេះ គឺជាពួក«កងទ័ពខ្មែរក្រហម»ដែលមាននិន្នាការម៉ៅនិយម ដែលជា«ក្រុមមេឃាតកររាស្ត្រខ្មែរ»យ៉ាងសាហាវឃោរឃៅក្រៃលែងនៃ<របបលានពិឃាត> ។ ក្រោយជ័យជំនះថ្ងៃទី១៧មេសាឆ្នាំ១៩៧៥ ស្ដេចសីហនុបានត្រូវពួកខ្មែរក្រហមនេះ លើកឲ្យឡើងធ្វើជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» រហូតទល់ខែមេសាឆ្នាំ១៩៧៦ ។

សរុបសេចក្ដីទៅ, ស្ដេចសីហនុពុំបានទៅ <ជួយ>យួនយៀកកុងយៀកណាមខាងជើងទេ ពីព្រះអង្គលើកស្លាក<ស្រុកខ្មែរ> ទៅ<ចុះចូល>ជាមួយតែម្ដង ។ ហើយលទ្ធផលចុងចប់ គឺព្រះអង្គត្រូវមកថោកទាបធ្វើជា<បាវបំរើនៃពួកអាយ៉ងយួន>ថែមទៀត (!!)

នេះហើយវាសនាកម្មខ្មែរដែលមានស្ដេចចោលម្សៀតដូច្នេះ ! ។ វប្បធម៌រាជានិយម ដែលបានចាក់គ្រឹះនៅក្នុងស្រុកខ្មែររាប់សតវត្សកន្លងមក ក៏ត្រូវមកអាប់ឱននិងបញ្ចប់ត្រឹមរាជ្យស្ដេចសីហនុនេះហោង ។៚

សម្លេងខ្មែរនៅបរទេស

# ស្ដេចសីហនុ ហើយនិងពួកខ្មែរសេរី

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី៣១ តុលា ១៩៩៦

ឪពុករបស់ខ្ញុំ លោកសុទ្ធ-កូម៉េត ធ្លាប់បានចូលគណបក្ស«ប្រជាធិបតេយ្យ»ក្បាលដីរបស់ទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស ។ ម្ល៉ោះហើយ កាលនៅក្មេង, ពីអាយុ៦ឆ្នាំទៅអាយុ១០ឆ្នាំ (១៩៤៩-១៩៥៣) ខ្ញុំតែងតែឃើញមានព្យួរនៅជញ្ជាំងផ្ទះរបស់ខ្ញុំជានិច្ចជាកាល នូវរូបរបស់រដ្ឋបុរសបីរូប ៖ សឺងង៉ុកថាន់, ស៊ីសុវត្ថិ-យុត្តិវង្ស និងអៀវ-កើស ។ ខ្ញុំធ្លាប់ឈរស្ដាប់ឪពុកខ្ញុំដោយភ្លឹកភ្លាំងនិងដោយស្ញើចសរសើរ ពេលណាគាត់ជជែកពិភាក្សាគ្នាអំពីនយោបាយជាមួយមិត្តភក្តិរបស់គាត់ ។ ដោយហេតុតែបានឃើញច្រើនដងពេកទៅ ខ្ញុំចាំរហូតដល់ពាក្យពេចន៍បាវចនានៃគណបក្ស «ប្រជាធិបតេយ្យ»សម័យនោះគឺ «វិន័យ-ថ្លៃថ្នូរ-ក្លាហាន» ។ ខ្ញុំចាំរហូតដល់ពាក្យបារាំងសរសេរនៅលើបដាក្នុងឱកាសហែរសពលោកអៀវ-កើស.. «Eternels regrets» (សេចក្ដីសោកស្ដាយដែលគ្មានទីចប់) ។ គឺបានសេចក្ដីថា តណ្ហានយោបាយច្រើនតែចម្លងពីឪពុកមកកូន...

ប៉ុន្តែតាំងពីសម័យដែលខ្មែរបានទទួលឯករាជ្យ (ខ្ញុំមានអាយុ១០ឆ្នាំ )... ខ្លួនខ្ញុំក៏ដូចជាក្មេងៗឯទៀតច្រើនគ្នាជំនាន់នោះ គឺមានឯករាជ្យខាងផ្លូវចិត្តរួចទៅហើយ...ដោយបានជាប់ចិត្តស្រឡាញ់ស្ដេចមួយអង្គ ដែលបានដណ្ដើមរាជ្យពីបារាំង ៖ សម្ដេចនរោត្តម-សីហនុ ។ ខ្ញុំធ្លាប់ភ្ញាក់ពីដំណេកនៅម៉ោងបួនភ្លឺ ដើម្បីស្លៀកពាក់ឯកសណ្ឋានខោខៀវអាវស ទៅហាត់ដើរដេហ្វីឡេ ។ ថ្ងៃក្រោយមក ខ្ញុំបានចូលក្នុងកងយុវ័ន ។ នៅវិទ្យាល័យទៀតសោត ខ្ញុំធ្លាប់បានសរសេរអត្ថបទក្រោមនាមប៉ាកា ផ្ញើទៅសារពត៌មានផ្សេងៗ ដើម្បីគាំទ្រសម្ដេចសីហនុដែលខ្ញុំធ្លាប់ស្រឡាញ់ ដូចតែគេស្រឡាញ់ឪពុកម្ដាយដូច្នោះ, មិនបានយកមកពិចារណាអ្វីទេ ។ រហូតដល់សម័យថ្ងៃមួយ ខ្ញុំភ្ញាក់ខ្លួនភ្លឺភ្នែក... ដោយឃើញអាការឃោរឃៅឥតប្រយោជន៍របស់ស្ដេច ៖ គឺពេលដែលតុលាការកាត់ទោសបាញ់ប្រហារជីវិតអ្នកនយោបាយប្រឆាំងម្នាក់ ឈ្មោះលោក«ព្រៀប-អ៊ិន»។ កាលនោះខ្ញុំមានអាយុ២២ឆ្នាំ... ចំណែកសេចក្ដីស្នេហាប្អូរផ្ដាច់របស់ខ្ញុំចំពោះ «សង្គមរាស្ត្រនិយម» ក៏របូតធ្លាក់ទៅតាមខ្សែទឹកស្ទឹង ហូរឥតវិលត្រឡប់ ។ នៅក្នុងបច្ចុប្បន្ននេះ ពុំសូវនរណានឹករលឹកឃើញដល់បទឧក្រិដ្ឋកម្មទាំងកណ្ដាលថ្ងៃត្រង់របស់សម្ដេចសីហនុ ទៅលើអ្នកតស៊ូខ្មែរសេរីនោះទេ... ប៉ុន្តែកាលសម័យនោះ គឺជាព្រឹត្តិការណ៍គ្រាប់បែកដែលផ្ទុះយ៉ាងខ្លាំងសំបើម ក្នុងសតិអារម្មណ៍ខ្មែរទូទៅ ។ ជាពិសេសនៅក្នុងមជ្ឈដ្ឋានចាស់ទុំដែលធ្លាប់តែគាំទ្រព្រះកូណាតាំងពីដើមរៀងមក... ក៏មានពាក្យថា ៖ «សម្ដេចសីហនុចូលក្នុងវ័យឆ្កួតឡប់សតិ ដូចតែព្រះកូណានរោត្តម ជាជីតារបស់ទ្រង់ ដែលបានបញ្ជាឲ្យគេបាញ់ប្រហារស្រីស្នំអស់៤-៥នាក់ក្នុងព្រឹកមួយ... ព្រោះតែមានចោរពានវាំង ។ បើតាមការយល់ឃើញរបស់ខ្ញុំផ្ទាល់... ការបាញ់ប្រហារលោកព្រៀប-អ៊ិន គឺជាជំហានទីមួយនៃរបប«សង្គមរាស្ត្រនិយម» ចូលទៅក្នុងសេចក្ដីវិនាសអន្តរាយ ។

ខ្ញុំមានអាយុ២២ឆ្នាំទៅហើយ ខ្ញុំធ្លាប់យល់និងធ្លាប់ពិចារណាថា អាការៈឃោរឃៅជាការចាំបាច់ នៅក្នុងធម្មជាតិនយោបាយ ។ គ្មានអ្នកនយោបាយណាម្នាក់ដែលមានដៃមិនប្រឡាក់នោះទេ ។ កាលសម្ដេចសីហនុបញ្ជាឲ្យលោក លន់-នល់ បាញ់លោក ដាប-ឈួន ដោយគ្មានជំនុំជំរះ... ហើយឲ្យអូសខ្មោចតាមកន្ទុយឡានកាម៉ុងទាហាន និងយករូបដាប-ឈួនទៅបិទនៅគ្រប់កន្លែងសាធារណៈដូចខ្មោចឆ្កែ... សេចក្ដីឃោរឃៅនេះបានបណ្ដាលឲ្យអ្នកផងញាក់សាច់គ្រប់គ្នា (កុម្ភៈ១៩៥៩) ។ ក៏ប៉ុន្តែ ខ្ញុំបានប្រៀបធៀបការឃោរឃៅនេះ ទៅនឹងលក្ខណៈសត្វខ្លា ដែលវាសម្លាប់សត្វរមាំងស៊ីជាអាហារ... គឺជាលក្ខណៈចាំបាច់នៃជីវិតវា ពីព្រោះវាមិនអាចទៅស៊ីស្មៅបានទេ ។ ម៉្យាងវិញទៀត, លោកដាប-ឈួនក៏មានលូកដៃចូលទៅក្នុងរដ្ឋប្រហារមួយដែលមិនបានសំរេច... លោកហាក់ដូចជាបានដឹងមុនជាស្រេចទៅហើយ អំពីល្បែងដ៏កាចសាហាវមួយ ដែលភ័ព្វព្រេងវាសនារបស់អ្នកចាញ់ គឺសេចក្ដីស្លាប់ ។



ដាប-ឈួន, មេដឹកនាំទ័ពព្រៃខ្មែរប្រឆាំងបារាំង, បានចេញមកសុំចុះចូលជាមួយស្ដេចសីហនុ កាលពីឆ្នាំ១៩៤៩ ។

ដូច្នេះហើយបានជាក្នុងព្រឹត្តិការណ៍ដាប-ឈួន បើទោះជាមានសេចក្ដីរន្ធត់ភិតភ័យភាំងស្មារតី ក៏ប្រជាពលរដ្ឋភាគច្រើនលើសលប់បានគាំទ្រសម្ដេចនរោត្តម-សីហនុ ។ ប៉ុន្តែការសម្លាប់ព្រៀប-អ៊ិនបន្ទាប់ពីសមាជាតិមួយ (ក្នុងឆ្នាំ១៩៦៥, បើខ្ញុំចាំមិនខុសទេ) បានធ្វើឲ្យស្ដេចសីហនុ លេចចេញលក្ខណៈឫស្យាឈ្នានិសព្យាបាទ ដូចតែស្ដេចអធិរាជ ណេរ៉ុង ដែលមានសេចក្ដីសោមនស្សរីករាយ ដេញចាប៉ីសើចច្រៀងសប្បាយ នៅពេលដែលឃើញទីក្រុងរ៉ូមឆេះ, គឺលក្ខណៈសប្បាយក្នុងការឃើញអ្នកដទៃឈឺចាប់វេទនា (Sadistic) ។ ការបាញ់ប្រហារលោកព្រៀប-អ៊ិនហើយនិងខ្មែរសេរីដទៃឯទៀតៗ... សម្ដេចសីហនុបានរៀបចំឡើង ដើម្បីសើចក្អាកក្អាយសប្បាយសំរួលព្រះទ័យប្រមាថមនុស្សស្លាប់ បើយោងតាមជំនឿប្រជាប្រិយ ប្រហែលគ្នានឹងសត្វខ្លែងស្រាក់ ដែលវាស្រែកចំអកបើកាលណាមានមនុស្សស្លាប់នៅក្នុងភូមិ ។ គិតសព្វៗទៅ បញ្ញវ័ន្តសេរី (ខៀវ)ទាំងនេះ ពុំបានប្រព្រឹត្តអ្វីខុសទាល់តែសោះ ។ កាលណាបានបាញ់ប្រហារពួកខ្មែរសេរីម្ដងៗ សម្ដេចសីហនុតែងប្រើពួកភ្នាក់ងារក្រសួងឃោសនាការទៅថតគ្រប់ជ្រុងជ្រោយ រួចហើយព្រះអង្គទ្រង់ប្រើឲ្យគេយកមកឲ្យទ្រង់ទតផ្ទៀងផ្ទុង... រួចហើយព្រះកូណាម្ចាស់ទ្រង់ព្រះរាជសំរួលក្អាកក្អាយ ។

ចំណែកខ្លួនខ្ញុំវិញ បើទោះជាចង់ឃើញ ឬក៏មិនចង់ឃើញ ក៏ខ្ញុំចៀសមិនរួច ពីទិដ្ឋភាពអមនុស្សធម៌នៃឃាតកម្មកណ្តាលថ្ងៃត្រង់ទៅលើរូបពួកខ្មែរសេរីដែរ...ដោយសម្តេចសីហនុព្រះប្រមុខរដ្ឋ ទ្រង់បានព្រះរាជបញ្ជា ឲ្យយកទៅចាក់បញ្ចាំងផ្សាយនៅគ្រប់ផ្ទាំងសំពត់ស គ្រប់រោងកុន... តាំងពីទីក្រុងរហូតដល់ស្រុកស្រែចំការ... តាំងពីឆ្នាំ១៩៦៥ ដល់១៩៦៧ ។

គឺជាការបញ្ចាំងផ្សាយដ៏ស្តែងអស្ចារ្យនូវការសម្លាប់មនុស្ស ដើម្បីបំពេរមោទនភាពរបស់ព្រះអង្គ ។ ម្ល៉ោះហើយខ្ញុំក៏បានឃើញទឹកមុខក្តួលក្តៅរបស់លោកព្រៀប-អ៊ិននៅចំពោះមុខសេចក្តីស្លាប់, បានឃើញសេចក្តីតក់ស្លុតរបស់លោកចៅ-បូរី, កំហឹងរបស់លោក មធុរ៉ា... ការសើចញញឹមញញែមរបស់លោកសៅ-ង៉ួយ ។ ខ្ញុំនៅចាំពេលគេចងខ្មែរសេរីផ្អោបនឹងបង្គោលនៅត្រពាំងក្រឡឹង រួចហើយគេចងមុខនឹងសំពត់ខ្មៅ... រួចហើយមានមនុស្សប្រហែល៧ទៅ៨នាក់ ឈរបាញ់ពីក្រោយខ្នងឡើងសុះសាច់ ។ ជនរងគ្រោះក៏ស្រុតជង្គង់គ្រឹប ចំតិតគូថឡើងលើ ចំណែកក្បាលសំយុងចុះក្រោម ។

បុគ្គលស្លាប់បាត់ទៅហើយ... ប៉ុន្តែជនម្នាក់ទៅចាប់សក់ក្បាលភ្ងើយឡើង ដើម្បីបន្ថែមមួយគ្រាប់ចុងក្រោយ (Coup de grâce) ដោយប្រើកាំភ្លើង P.A. Colt ។ ប្រហែលដោយសារព្រលឹងចេញមិនទាន់អស់ ឬក៏ដោយសារកម្លាំងគ្រាប់កាំភ្លើង ក្បាលនោះក៏ភ្ញាក់កន្ត្រាក់ម្តងទៀត... រួចសំយុងធ្លាក់ចុះទៅវិញ នៅពេលដែលលេចចេញប្រហោងគ្រហ៊ូរផ្លែអង្គុញនៅត្រង់ម្តុំសៀតផ្កា ។ ទិដ្ឋភាពប្រហោងមូលថ្លុញដូចភ្នែកបិសាច បានតាមលង់សតិអារម្មណ៍របស់ខ្ញុំយ៉ាងយូរលង់ ។

នៅពេលដែលរបប«សង្គ្រាស្រ្តនិយម»កំពុងរក៌រីក្នុងការចងបាញ់បញ្ញវ័ន្តខ្មែរសេរី..ដូចជាបាន២-៣នាក់រួចហើយ, កាសែតបារាំងឈ្មោះ «Le Canard Enchaîné» ដែលមានគោលជំហរប្រឆាំងនឹងការសម្លាប់មនុស្ស ទោះជាមនុស្សប្រភេទណាក៏ដោយ, ក៏បានប្រកាសលែងទទួលស្គាល់សម្តេចសីហនុ ក្នុងនាមជាអ្នកនិពន្ធម្នាក់នៅក្នុងទំព័ររបស់ខ្លួនទៀតហើយ ។ សម្តេចក៏បានឆ្លើយតបវិញដោយកំហឹង... ដោយប្រើលោកហ៊ុយ-ហែមឲ្យគូរគំនូរ «Le Canard Enchaîné» ជាសត្វទាមួយមានពាក់សញ្ញា «ណាស៊ី», បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «Kambuja» ។ នេះជាសក្ខីភាពមួយបង្ហាញថា ស្តេចសីហនុមានសេចក្តីកំណាចឃោរឃៅ រហូតដល់មានការឆ្កួតលីលានៅក្នុងសតិអារម្មណ៍ លែងដឹងខុសត្រូវ, ខ្លួនឯងយកប្រជាពលរដ្ឋខ្មែរធ្វើជាខ្មាំងសត្រូវ ហើយបែរទៅចោទកាសែតបារាំងថាជាកាសែត«ណាស៊ី»...

ប្រសិនបើប៉ុល-ពតជាសត្វពស់, កាលក្នុងសម័យដែលសម្តេចសីហនុចាត់ឲ្យគេបាញ់ប្រហារពួកខ្មែរសេរីនោះ, ប៉ុល-ពតគ្រាន់តែជាពស់ក្នុងពង (Le serpent était dans l'oeuf) ។ ចំណែកសម្តេចសីហនុនេះឯងជាមេពស់... គឺជាសត្វពស់កេងកង ។ ទៅថ្ងៃក្រោយទៅ... ពួកខ្មែរក្រហមដើរកាប់សម្លាប់អ្នកស្រុក ហ៊ោរកព្រៀវខ្សៀវខ្វារ សម្លាប់ក្មេងក្នុងអង្រឹង, សម្លាប់ស្រីមានផ្ទៃពោះ, មានការសើចសប្បាយដោយឈ្នានិសព្យាបាទ... នៅពេលដែលឃើញអ្នកក្រុងទៅដួលស្លាប់នៅវាលស្រែ...ពួកខ្មែរក្រហមពុំមែនមានត្រឹមតែសាឡុត-សរ ហៅប៉ុល-ពត ជាគ្រូបាធ្យាយ៍ប៉ុណ្ណោះទេ...ប៉ុន្តែមានសម្តេចសីហនុ ជាសាស្រ្តាចារ្យដើមចម... ជារៀមច្បងផ្នែកទារុណកម្ម ។

* * *

# លោកព្រៀប-អ៊ិន

ពេលត្រូវយកទៅកាត់ទោសប្រហារជីវិត ដោយបញ្ជារបស់ស្តេចសីហនុ, លោកព្រៀប-អ៊ិនជាបញ្ញវ័ន្តខ្មែរក្មេងម្នាក់ មានអាយុប្រមាណជាង ៣០ឆ្នាំ ។ មាឌស្តមខ្ពស់, រាងចំអឹង ប្រកបដោយថ្វាសវែង សក់រួញ...មុខមាត់ធ្វើឲ្យខ្ញុំនឹករលឹកឃើញដល់លោកអៀវ-កើស...។ ប្រសិនបើលោកព្រៀប-អ៊ិន ត្រូវរបបរបស់ស្តេចសីហនុចាប់ខ្លួនបាន ក៏មតិមហាជនមិនបានសួរជាប្រកាន់ប្រកួតអ្វីដែរ...ប៉ុន្តែស្តេចសីហនុជាអ្នកល្បួងបោកព្រៀប-អ៊ិនយកមកសម្លាប់ ដែលជាការក្បត់សីលធម៌នៃនយោបាយទូត ។ លោកព្រៀប-អ៊ិនមិនបានមកធ្វើវិទ្ធ្វេតកម្ម បំផ្លាញស្ពាន ដុតផ្ទះអ្នកស្រុក ឬប្រយុទ្ធជាមួយកងទ័ពជាតិ ឬក៏ចូលមកឃោសនាធ្វើវិទ្ធង្សនា បំផ្លាញរបបសង្គមរាស្រ្តនិយមនៅប្រទេសកម្ពុជានោះទេ ។ ក្រៅពីវត្តមាននៃវិទ្យុខ្មែរសេរីមួយនៅព្រៃនគរ (ខ្លួនខ្ញុំផ្ទាល់...មិនទាំងដែលបានស្តាប់សម្លេងវិទ្យុនោះម្តងផង... ធ្លាប់តែស្តាប់វិទ្យុរបស់សម្តេច)... ចលនាខ្មែរសេរីក្រោមការដឹកនាំរបស់លោកសឺង-ង៉ុកថាន់ មិនដែលទៅប៉ះពាល់ប្រយោជន៍ភូមិដ្ឋានខ្មែរ ដែលស្ថិតនៅក្រោមរបបស្តេចនោះបន្តិចបន្តួចសោះ, ផ្ទុយពីចលនាខ្មែរក្រហម ។ មិនត្រឹមតែប៉ុណ្ណោះ, ថ្ងៃក្រោយមក នៅខែមករាឆ្នាំ១៩៦៩, មានពួកខ្មែរសេរី២០៥នាក់ បានមកចុះចូលក្នុងរបបរបស់សម្តេចសីហនុ...។ ទំនងមើលទៅលោកសឺង-ង៉ុកថាន់បានអនុញ្ញាតឲ្យពួកខ្មែរសេរីទាំងនេះ មកពួកកម្លាំងគ្នាជាមួយសម្តេចសីហនុ ដើម្បីទប់ទល់នឹងការរាតត្បាតរបស់យៀកកុង (លោកសឺង-ង៉ុកថាន់ បានគិតប្រយោជន៍ជាតិខ្មែរជាមុន, មិនបានគិតប្រយោជន៍ផ្ទាល់ខ្លួននោះទេ...) ។ តើនរណាអាចដឹងជាមុនបាន ថាស្តេចសីហនុបែរជារត់ទៅចូលយៀកកុងដើម្បីវាយប្រហារប្រទេសជាតិរបស់ខ្លួនឯង ? ។ នៅក្នុងរឿងក្បត់ជាតិរបស់សម-សារី និងលោកដាប-ឈួនទៀតសោត... មានស្នាមប្រឡាក់ប្រឡូសរបស់រដ្ឋការយៀកណាមខាងត្បូង ង៉ោ-ឌិនយៀម និងង៉ោ-ឌិនញូ... ប៉ុន្តែពុំបានត្រាសញ្ញារបស់សឺង-ង៉ុកថាន់ទាល់តែសោះ...។ សំរេចសំរួចទៅ លោកសឺង-ង៉ុកថាន់ក៏ដូចជាលោកលន់-នល់... ប្រវត្តិសាស្រ្តនៅតែចងចាំថា ជាអ្នកនយោបាយរេរា ស្ទាក់ស្ទើរ... នៅទីបំផុតជាអ្នកសំរេចឲ្យស្តេចនៅរស់, ស្របតាមពាក្យស្លោកថា ៖ «ចិត្តមិនដាច់ ធ្វើស្តេចមិនបាន» ។ ចំណែកប៉ុល-ពតនិងពួកខ្មែរក្រហមជារឿងផ្សេង...ប៉ុល-ពតបានទាញមេរៀនគ្រប់យ៉ាងពីសេចក្តីទន់ខ្សោយរបស់សឺង-ង៉ុកថាន់និងរបស់លោកលន់-នល់ជាមួយស្តេច ។

ត្រឡប់មកលោកព្រៀប-អ៊ិនវិញ... លោកជាខ្មែរសេរីទី១ ដែលសម្តេចបានល្បួងយកមកបាញ់ចោលជាសាធារណៈ។ លោកព្រៀប-អ៊ិនបានចូលមកស្រុកខ្មែរ ក្នុងគោលបំណងល្បួងសម្តេចសីហនុ ឲ្យចេញពីមាគ៌ានយោបាយកុម្មុយនិស្ត, ចំណែកស្តេចសីហនុវិញ មានគោលបំណងល្បួងគេឲ្យចុះចូលនឹងខ្លួន...។ ទាំងនេះសុទ្ធសឹងតែជាការយល់ច្រឡំនៃភាគីទាំងសងខាង...។ អ្នកដែលបានធ្វើជាអាជ្ញាកណ្តាល ដើម្បីទាក់ទាញលោកព្រៀប-អ៊ិន មកឲ្យចូលក្នុងសំណាញ់របស់ស្តេច គឺលោកអ៊ិន-តាំ ចៅហ្វាយខេត្តតាកែវ ។ ថ្ងៃក្រោយមកទើបខ្ញុំដឹងថា លោកព្រៀប-អ៊ិនត្រូវជាក្មួយរបស់លោកអ៊ិន-តាំ... ហើយនៅពេលដែលលោកព្រៀប-អ៊ិនបានត្រូវបាញ់ប្រហាររួចហើយ ។ ក្រុមគ្រួសាររបស់លោកអ៊ិន-តាំបានស្តីបន្ទោសឲ្យគាត់ជាច្រើន ។ យោងតាមប្រភពខ្លះ លោកអ៊ិន-តាំបានបញ្ចេញវាចាយ៉ាងដូច្នេះ ៖ «ព្រៀប-អ៊ិន, ខ្ញុំជួយវាមិនរួចទេ ។ វាសមតែស្លាប់ដូច្នេះ... ពីព្រោះវាមាត់រឹង ព្រហើនមិនព្រមលន់តួជាមួយសម្តេចសីហនុ» ។ តាមពិតលោកព្រៀប-អ៊ិនបានពោលប្រាប់ស្តេចសីហនុថា ខ្លួនលោកពុំមែនមកចុះចូលជាមួយសម្តេចទេ លោកចូលមកក្នុងឋានៈជាអ្នក

ចរចា ។

ខ្ញុំនៅនឹកឃើញដូចកាលពីម្សិលមិញ អំពីថ្ងៃដំបូងដែលខ្ញុំបានជួបប្រទះនឹងព្រឹត្តិការណ៍ព្រៀប-អ៊ិន ។ គឺជាឱកាសពិធីប្រារព្ធសមាជជាតិដែលចូលមកដល់ថ្ងៃទី២ទៅហើយ... ខ្ញុំបានជិះម៉ូតូ ម៉ូប៊ីឡែត ពណ៌ខៀវរបស់ខ្ញុំទៅកន្លែងវាលមេរុ នៅម៉ោង១១ព្រឹក, ទៅទីកន្លែងដែលមនុស្សតូចធំទាំងឡាយមកពីគ្រប់ខេត្តខ័ណ្ឌ មករួមប្រជុំធ្វើសមាជ ។ ខ្ញុំបញ្ឈប់ម៉ូតូនៅក្បែរកំផែងវាំង ហើយកំពុងតែទិញម្នាក់ត្រាំមួយពីចិន... ស្រាប់តែខ្ញុំឃើញមនុស្សជាប់ទ្រុងម្នាក់ពីមាត់ទន្លេ ។ គឺជាទ្រុងមួយខ្ពស់ដាក់នៅលើឡាន ប្រកបដោយចរឹងដែក មានដំបូលរាងមូល និងមានពណ៌ប្រហែលគ្នានឹងក្លោះរបស់ស្តេច ។ មនុស្សនៅក្នុងទ្រុងពាក់អាវស ឈរផ្អឹងនឹងថ្កល់... ចំណែកមនុស្សនៅខាងក្រៅរាប់រយនាក់ រត់តាមយកដុំថ្មដុំគ្រួសដុំដី មកគប់លើជនជាប់ទ្រុងនេះ ដូចគេគប់ទៅលើស្វាតឹងកុង ដោយជេរប្រទេចផ្តាសារថា ជា«ជនក្បត់ជាតិ» ។ បុរសក្បត់ជាតិនោះហើយ គឺជាលោកព្រៀប-អ៊ិន...។ ចំណែកសម្តេចសីហនុ បង្ខិលមេក្រូដូចគេបង្ខិលកាំភ្លើងមីត្រៃយ៉ើ... ដើម្បីពន្យុះឲ្យមហាជនខឹងក្រេវក្រោធចំពោះជានជាប់ទោស ។ ខ្ញុំមើលទៅសីហនុ ឃើញដូចជាស្តេចអធិរាជ រ៉ូម៉ាំងដែលពន្យុះរាស្ត្រប្រជា ឲ្យស្រែកហ៊ោរកញ្ច្រៀវ នៅពេលដែលចាប់មនុស្សបោះឲ្យខ្លាស៊ី ។ នៅពេលនោះ សម្តេចសីហនុហាក់ដូចជាពោលមកខ្ញុំថា ៖ «អញជាស្តេច ! ចំណែកពួកឯងជាសត្វ... អញធ្វើអីក៏ភ្លឹង តើនរណាហ៊ានធ្វើអីអញ ?» ។ ទ្រុងរបស់លោកព្រៀប-អ៊ិន ក៏ខិតមកជិតខ្ញុំបន្តិចម្តងៗ... ខ្ញុំទ្រាំមិនបាននឹងទិដ្ឋភាពនេះ ក៏បត់ក្បាលម៉ូតូចេញជាប្រញាប់ ។

* * *

## លោកសៅ-ង៉ូយ

គឺជាបញ្ញវ័ន្តសេរីចុងក្រោយ ដែលស្តេចសីហនុបានចាប់បាញ់ចោលនៅត្រពាំងក្រឡឹងបង្ហាញសាធារណជន ។ ...បន្ទាប់ពីលោកសៅ-ង៉ូយទៅ, សម្តេចសីហនុហាក់ដូចជា (បាក់ទឹកចិត្ត) លែងចាប់មនុស្សមកប្រហារសំដែងឫទ្ធិបញ្ចូលហ្វីលកុនតទៅទៀត ។ ការប្រហារជីវិតរបស់លោកសៅ-ង៉ូយ បានប្រព្រឹត្តទៅនៅក្នុងខែឧសភាឆ្នាំ១៩៦៧ ។ ខ្ញុំនៅចាំយ៉ាងច្បាស់បំផុតអំពីព្រឹត្តិការណ៍នេះ... ដោយហេតុថាក្នុងសម័យគេចាប់ខ្លួនលោកសៅ-ង៉ូយ ខ្ញុំកំពុងតែសរសេរប្រលោមលោកមួយឈ្មោះថា «ចំតិតឥតអាសូរ» ។ សារពត៌មាន«សុជីវធម៌»របស់លោកនុត-ឈឿមក៏បានចោទប្រកាន់ខ្ញុំមួយរំពេច ថាជាអ្នកនិពន្ធ«ខ្ទះការអប់រំ» ហើយដែលមានខួរក្បាល«បរទេស» ។ ចំណែកក្រសួងឃោសនាការ ក្រោមការដឹកនាំរបស់អ្នកស្រី ជិន-រ៉េន ក៏បានផ្សាយតាមវិទ្យុ មួយថ្ងៃបីដង អស់ចំនួនពីរថ្ងៃថា «បុគ្គលណាដែលភ្នាក់ងារមានសមត្ថភាពទាន់ខ្លួនកំពុងអានសៀវភៅ <ចំតិតឥតអាសូរ> នឹងត្រូវកោះហៅទៅសាលាដំបូង » ។

តាមពិតខ្ញុំសរសេរសៀវភៅនេះ ដោយនឹកឃើញដល់មនុស្សពីរនាក់... គឺធ្មេញជ័យ (ធនញ្ជ័យ) ហើយនិងសៅ-ង៉ូយ ។ ធ្មេញជ័យ...ដោយហេតុតែស្តេចមិនចង់ឃើញមុខរបស់គាត់... គាត់ក៏ចំតិតគូថថ្វាយទ្រង់នៅតាមបង្អួច ។ បើព្រះអង្គមិនសព្វព្រះទ័យអាខាងមុខ ខ្លួនក៏សំរេចចិត្តថ្វាយអាខាងក្រោយ ។ ចំណែកលោកសៅ-ង៉ូយវិញ ព្រះរាជាបានចាប់ចងបាញ់ ស្រុតក្បាលជង្គង់ដល់ដីហើយ ក៏នៅតែឆ្លៀតចំតិតឲ្យព្រះរាជាដែរ... ក្នុងន័យថា ជាការប្រឆាំងគ្មានចប់ (Défi absolu) ។ ថ្ងៃក្រោយទៅ ខ្ញុំបានយក«ចំតិតឥតអាសូរ» ទៅបកប្រែជាភាសាបារាំង ដោយដាក់ចំណងជើងថា «L'Anarchiste» ។



លោកសៅ-ង៉ូយ នៅមុនពេលបាញ់បានសុំបឺតបារីមួយខ្សឹត រួចស្រែកយ៉ាងខ្លាំងឡើងថា « ជយោសម្តេចព្រះនរោត្តម-សីហនុ !» ។

លោកសៅ-ង៉ូយជាបញ្ញវ័ន្តចេះដឹង ធ្លាប់បានធ្វើការសិក្សាជាន់ខ្ពស់ រហូតដល់បានជាប់ថ្នាក់ឧត្តមមន្ត្រី ។... គឺជាសភាពបុរសម្នាក់ ដែលមានរូបរាងសង្ហារ មានឆ្អឹងរឹងដូចដែក មានកម្លាំងមាំមួន អាចប្រយុទ្ធគ្នាមួយទល់នឹងប្រាំ ។ លោកសៅ-ង៉ូយមានសេចក្តីក្លាហានផ្នែកកាយសម្បទា ដោយយកម្រេះកនរណាប្រៀបប្រដូចបាន... គឺមិនចេះតក់ស្លុតនឹងគ្រោះថ្នាក់ ។ កាលនៅរៀនឯវិទ្យាល័យស៊ីសុវត្ថិ លោកសៅ-ង៉ូយធ្លាប់ចូលតយុទ្ធនឹងពួក Normal ដោយដៃទទេ ។, ថ្វីបើខាងម្ខាងទៀតមានមាឌធំជាង មានគ្នាច្រើនជាង ព្រមទាំងប្រដាប់ដោយអាវុធកាំបិត-ពូថៅ...។ បើនៅក្នុងភូមិណាសំបូរដោយចោរលួចចោរប្លន់ លោកសៅ-ង៉ូយចូលចិត្តជិះកង់ទៅតែម្នាក់ឯងធ្វើព្រងើយ ។ ប៉ុន្តែជាការអកុសល ពេលនៅវ័យជំទង់ លោកសៅ-ង៉ូយបានទះមនុស្សម្នាក់ដោយជ្រុលដៃ ដោយគ្រោះថ្នាក់ (នៅជ្រោយអំពិល) ។ រឿងនេះសាមីខ្លួនបានលាក់បាត់ទៅ ក្លាយទៅជាអាថ៌កំបាំងទៅហើយ ។ ប៉ុន្តែថ្ងៃក្រោយមក នៅពេលចេញធ្វើជាឧត្តមមន្ត្រី... លោកសៅ-ង៉ូយបានដណ្តឹងកូនថៅហ្វាយស្រុកម្នាក់ធ្វើជាប្រពន្ធ ហើយក៏បានយកអាថ៌កំបាំងរបស់ខ្លួនទៅរ៉ាយរ៉ាប់ប្រាប់នាងប្រពន្ធអស់រលីង ។ ហេតុតែស្នេហានាង ដាលីឡា សាំសុងក៏បានទទួលគ្រោះថ្នាក់ ។ នាងអាលីន, ប្រពន្ធលោកសៅ-ង៉ូយ, ជាស្រីម្នាក់មានសម្ផស្សប្រិមប្រិយ មានកំពស់កំព ទុកសក់ជាកំប៉ោយទៅក្រោយដូចសក់សេះ គួរជាទីចាប់ចិត្តមេត្រីខ្លាំងណាស់... (ថ្ងៃក្រោយទៅ នាងអាលីនបានក្លាយទៅជាភរិយាលោកសុក-ឆុង) ។ នាងអាលីនក៏បានយកអាថ៌កំបាំងរបស់ប្តី (សៅ-ង៉ូយ)ទៅប្រាប់ឪពុកម្តាយគ្មានសល់ ។ ដោយលោកសៅ-ង៉ូយជាមន្ត្រីស្មោះត្រង់ មិនសូវចេះរកស៊ីក្រៅហើយនៅតែក្រ លោកសៅ-ង៉ូយក៏ចេះតែធ្វើឲ្យទាស់ចិត្តដល់ឪពុកម្តាយក្មេក ។ រឿងអាក់អន់ចិត្តបន្តិចបន្តួចក៏ក្លាយទៅជារឿងធំ រហូតដល់ឪពុ



សៅ-ង៉ូយ, នៅក្រោយពេលបាញ់ប្រហារជីវិត ២២/៥/៦៧

កម្ដាយក្មេកយកសំណុំរឿងរបស់លោកសៅ-ង៉ូយ (សម្លាប់មនុស្ស) ទៅប្ដឹងតុលាការ ។ លោកសៅ-ង៉ូយដឹងខ្លួនទាន់ ក៏បានគេចខ្លួនទៅប្រទេសលាវ រួចទៅព្រៃនគរ ចូលក្នុងចលនាខ្មែរសេរីរបស់លោកសឺង-ង៉ុកថាន់ ។ បូករួមសេចក្ដីទាំងអស់ទៅ... លោកសៅ-ង៉ូយពុំមែនជាអ្នកនយោបាយទេ ។ លោកពុំបានរត់ចេញពីស្រុកខ្មែរ ដោយសារស្អប់ស្ដេចនោះទេ... ប៉ុន្តែដោយសារលោកមានវិបត្តិជាមួយនឹងគ្រួសារខ្លួនឯង ។

ការចាប់ខ្លួនរបស់លោកសៅ-ង៉ូយទៀតសោត ប្រៀបបានទៅនឹងការចាប់ខ្លួនរបស់ព្រៀប-អ៊ិនដែរ, គឺបានប្រព្រិត្តទៅដោយវិធីល្បួងបោកបញ្ឆោត ។ មានភ្នាក់ងារកងទ័ពបានទៅបបួលលោកសៅ-ង៉ូយផឹកស្រាទាល់តែស្រវឹងលែងដឹងខ្លួននៅព្រៃនគរ ។ លុះដល់សៅ-ង៉ូយភ្ញាក់ដឹងខ្លួនកាលណា ក៏បានមកដល់មន្ទីរឃុំឃាំងរបស់ស្ដេចសីហនុរួចទៅហើយ ។ មានអន្តរាគមន៍ជាច្រើនមជ្ឈដ្ឋាន ស្នើសុំឲ្យព្រះប្រមុខរដ្ឋលើកលែងទោសឲ្យសៅ-ង៉ូយ... ប៉ុន្តែស្ដេចសីហនុមានសេចក្ដីមានះដាច់ខាត សូមចងកម្មចងពៀរជាមួយនឹងមនុស្សម្នាក់ ដែលគ្មានរឿងអ្វីទាក់ទាមនឹងព្រះអង្គសោះ ។

នៅពេលដែលតុលាការសឹកចាប់យកទៅសួរចម្លើយ...គេបានចោទសួរលោកសៅ-ង៉ូយដូច្នេះថា ៖ (ពត៌មាននេះ ខ្ញុំបានទទួលពីនាយទាហានជាន់ខ្ពស់ម្នាក់ ធ្វើការនៅការិយាល័យទី២ ឈ្មោះគឹម-ទ្រឿង) ៖

- តើលោកជាអ្នកស៊ីឈ្នួលបំរើអាមេរិកាំងពិតមែនឬ (តុលាការ) ។
- ខ្ញុំរស់ដោយសារអាមេរិកាំងពិតមែន... ប៉ុន្តែខ្ញុំគ្មានបានធ្វើអ្វីបំរើអាមេរិកាំងទេ (សៅ-ង៉ូយឆ្លើយ) ។

នៅទីបំផុត តុលាការសឹកបានសំរេចប្រហារជីវិតលោកសៅ-ង៉ូយស្របតាមឆន្ទៈព្រះប្រមុខរដ្ឋ (កាលណាមានព្រះរាជអំណោយ នោះជារបស់សម្ដេចឪ... កាលណាមានការពិឃាត នោះជារបស់តុលាការសឹក)

នៅរាត្រីមុនថ្ងៃពិឃាត, ភ្នាក់ងារនៃក្រសួងមានសមត្ថកិច្ច ក៏បានទៅសាកសួរលោកសៅ-ង៉ូយថា តើលោកចង់បានអ្វីមុនថ្ងៃប្រហារជីវិត ? ។ លោកសៅ-ង៉ូយក៏បានសុំស្រានិងបារី ហើយនិងស្រីម្នាក់...។ គេបានប្រគល់ជូនលោកនូវស្រានិងបារី... ប៉ុន្តែបានបដិសេធស្រី ។

នៅថ្ងៃប្រហារជីវិត... ប្លែកពីអ្នកទោសមុនៗ, លោកសៅ-ង៉ូយបានដើរយ៉ាងសង្ហារឆ្ពោះទៅបង្គោលមច្ចុរាជ ដោយគ្មានចាំបាច់នរណាគ្រា ឬរុញច្រានសោះឡើយ ។ លោកសៅ-ង៉ូយប្រហែលជាមិនចេះរស់ស្របតាមសង្គមនិយមរបស់សម្ដេចសីហនុ... ប៉ុន្តែលោកចេះស្លាប់ដោយថ្លៃថ្នូរដូចវីរៈបុរស ។ លោកញញឹមញញែមគ្មានតក់ស្លុត គ្មានព្រឺព្រួច ទទួលយកសេចក្ដីស្លាប់ដូចគេបានទទួលអម្រិត្យត្រជាក់ ។ នៅពេលដែលគេចងរឹតក្រៀកលោកជាចុងបង្អើយ... លោកសៅ-ង៉ូយខំប្រឹងបឺតបារីដល់ទីចប់ ។ តាមប្រភពខ្លះបានឲ្យខ្ញុំដឹងថា... នៅមុនពេលដែលគេបានបាញ់ប្រហារ... លោកសៅ-ង៉ូយបានស្រែកថា ៖ «ជយោ ! សម្ដេចព្រះនរោត្តម-សីហនុ !» ។

*     *
*

នៅថ្ងៃក្រោយមក... សម្ដេចសីហនុបានបដិសេធទាំងស្រុង ថាដែលោកពុំមានប្រទ្បាក់ប្រទ្បូសក្នុងការប្រហារជីវិតជនណាម្នាក់សោះឡើយ ។ បើយោងតាមពាក្យសំដីរបស់ទ្រង់ សូម្បីតែសត្វរុយនិងសត្វមូសមួយ ក៏លោកមិនទាំងដែលបានដកស្រង់យកជីវិតរបស់គេផងដែរ ។

នៅក្នុងឆ្នាំ១៩៨០ ស្ដេចសីហនុបានបោះពុម្ពសៀវភៅជីវៈប្រវត្តិរបស់គាត់មួយនៅទីក្រុងប៉ារីស... ដែលមានចំណងជើងថា «Souvenirs doux et amers» ។ នៅក្នុងទំព័រទី១៣១ ស្ដេចសីហនុបានសរសេរដូចតទៅនេះ ៖ «ខ្ញុំក៏អាចក្លាយទៅជាស្ដេចម្នាក់ចិត្តល្អបានដែរ... អ្នកខ្លះបានពោលថា ខ្ញុំនេះជាមនុស្សកាចសាហាវខ្លាំងណាស់ចំពោះគូសត្រូវរបស់ខ្ញុំ ។ តាមការពិត ខ្ញុំធ្លាប់កាចតែត្រឹមពាក្យសំដី... មានពេលខ្លះខ្ញុំខឹងច្រឡោតដាច់ក្បាលកន្ទុយទៀតផង ចំពោះឥស្សរជនខ្លះដែលចង់បំផ្លាញរូបខ្ញុំ ប៉ុន្តែ<ការឃោរឃៅ>របស់ខ្ញុំ មិនដែលទៅឆ្ងាយហួសពីពាក្យសំដីនោះឡើយ... ចំណែក<ពួកអ្នករងគ្រោះរបស់ខ្ញុំ>នៅតែមានជីវិតរស់នៅនិងមានសុខភាពល្អជានិច្ច នៅពេលដែលខ្ញុំត្រូវបង្ខំចាកចេញពីអំណាច» ...ហេ ! ហេ ! ឥតវាចានឹងថ្លែង (!!)...

**« Il m'arrive d'être bon prince. On a parfois dit que j'étais impitoyable envers mes ennemis. En réalité, s'il m'est arrivé plus d'une fois de m'exprimer très vivement, à l'encontre de personnalités qui cherchaient à me nuire, ma (violence) n'a que bien rarement dépassé le stade verbal et mes (victimes) se portaient toujours bien quand j'ai dû quitter le pouvoir. » ( Souvenirs doux et amers - Paris 1980- Hachette -p.131 par Norodom Sihanouk)** ។

នៅថ្ងៃក្រោយមកទៀត, ក្នុងឆ្នាំ១៩៨៧, ស្ដេចសីហនុមានជម្លោះជាមួយនឹងអ្នកសារពត៌មានអាមេរិកាំងម្នាក់ឈ្មោះ Elizabeth Becker ដែលបានផ្សាយពីការពិឃាតទៅលើពួកអ្នកជំទាស់នយោបាយ... បង្គាប់បញ្ជាដោយសម្ដេច ។ នៅក្នុងរឿងនេះ, លោក Bernard Hamel ដែលធ្លាប់ធ្វើជាអ្នកឆ្លើយឆ្លងទីភ្នាក់ងារពត៌មាន Reuters ប្រចាំនៅភ្នំពេញពីឆ្នាំ១៩៦៥ដល់១៩៧៥ បានផ្ដល់នូវភស្តុតាងមិនអាចប្រកែកបាន ហើយដែលគាំទ្រការអះអាងរបស់អ្នកស្រី Becker, ភស្តុតាងដែលចុះផ្សាយដោយទស្សនាវដ្ដី Far Eastern Economic Review ហើយដែលបានបញ្ចប់ជម្លោះរវាងអ្នកទាំងពីរ ។ ភស្តុតាងនោះ គឺរូបថតនៃការបាញ់ប្រហារពួកខ្មែរសេរី ថតដោយភ្នាក់ងារក្រសួងឃោសនាការនៃសង្គមរាស្ត្រនិយមរបស់ស្ដេចសីហនុ រក្សាទុកដោយលោក Bernard Hamel (រូបថតដែលមានចុះផ្សាយនៅក្នុង«អង្គរបុរី»លេខនេះ និងលេខរួចមកហើយ) ។

តទៅនេះជាសេចក្ដីនៃលិខិតរបស់លោក Bernard Hamel ចុះផ្សាយថ្ងៃទី២១ ឧសភា ១៩៨៧ ដែលមានភ្ជាប់ដោយរូបថតពីសន្លឹកនៃការពិឃាតនោះផង ៖ «រូបនេះ បង្ហាញពីការចាប់ផ្ដើមបាញ់ប្រហារជីវិតពួកខ្មែរសេរី... ដែលប្រព្រិត្តទៅរហូតដល់ឆ្នាំ១៩៦៧ ។ តើអស់ចំនួនប៉ុន្មាននាក់? ទំនងដូចជា១២នាក់... បើតាមខ្ញុំដឹង (លោក Bernard Hamel សរសេរ) មាន ៖ ព្រៀប-អ៊ិន, ចៅ-បូរី, ប្អូនរបស់ចៅ-បូរី...មធុរ៉ា, សៅ-ង៉ូយ, ចៅ-ស៊ី ហើយនិង ង៉ែត-ងិន ។ តាមបញ្ជារបស់សម្ដេច ការប្រហារជីវិតនៃជនទាំងនេះ ត្រូវបានចាក់ផ្សាយពាសពេញព្រះរាជាណាចក្រ» ៕

# ស្ដេចសីហនុជាមួយយួន និងពួកខ្មែរក្រហម

ខាងក្រោមនេះ គឺជាកាលប្បវត្តិខ្លះៗអំពីទំនាក់ទំនងរវាងស្ដេចសីហនុជាមួយពួកយួននិងខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ដែលយើងធ្វើការដកស្រង់ខ្លះៗចេញពីសៀវភៅ<Les clés du Cambodge> សរសេរដោយលោក Raoul M. Jennar បោះពុម្ពផ្សាយកាលពីឆ្នាំ១៩៩៥ ៖

## ★ ឆ្នាំ១៩៧០

- ថ្ងៃទី១៨ មិនា ៖ សីហនុចាកចេញពីក្រុងមូស្គូទៅក្រុងប៉េកាំង ជាកន្លែងគាត់ជួបជាមួយគណប្រតិភូបក្សកុម្មុយនិស្តកម្ពុជា ក្រោមការដឹកនាំរបស់សាឡុត-សរ ។
- ថ្ងៃទី១៩ មិនា ៖ ការប្រកាសភាពអាសន្ន ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកចាត់ទុកការទម្លាក់សីហនុត្រឹមត្រូវតាមច្បាប់ ។ នៅភ្នំពេញការធ្លាក់របស់សីហនុ បានទទួលនូវការពេញចិត្ត ពីសំណាក់ពួកយុវជននិងនិស្សិត ជាពិសេសក្នុងចំណោមពួកបញ្ញវ័ន្ត ដែលគេជឿថាដូចការកើតឡើងម្ដងទៀតនៃបដិវត្តន៍បារាំងឆ្នាំ១៧៨៩ ។ ពួកយុវជនជាច្រើនម៉ឺននាក់ បាននាំគ្នាស្ម័គ្រចិត្តចុះឈ្មោះចូលធ្វើទាហាន ដែលក្នុងរយៈពេល៩ខែសោះ កងទ័ពបានកើនពី៣៥,០០០ទៅដល់១៥០,០០០នាក់ ។
- ថ្ងៃទី២៣ មិនា ៖ សីហនុប្រកាសនៅប៉េកាំង បង្កើតរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) ដោយមានការគាំទ្រពីប្រទេសចិន, យួនខាងជើង នឹងយៀកកុង ។ រណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) មានការចូលរួមពីពួកសីហនុនិយម ក៏ប៉ុន្តែក៏មានផងដែរនូវពួកគណបក្សកុម្មុយនិស្តកម្ពុជា ។ រណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជាក៏បានបង្កើតកងទ័ពរបស់ខ្លួនផងដែរ ដែលគេដាក់ឈ្មោះថា ៖ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK) ។
- ថ្ងៃទី២៤ មិនា ៖ សីហនុចេញសេចក្ដីអំពាវនាវមួយ ដើបអាវុធប្រឆាំងរបបលន់-នល់ ។ ការរាលដាលនៃសង្គ្រាមវៀតណាមមកកម្ពុជា ចាប់ពីឥឡូវនេះទៅ បានបន្ថែមនូវសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ។ មានការខ្វែងគំនិតរវាងពួកកុម្មុយនិស្តខ្មែរ និងពួកកុម្មុយនិស្តយួន នៅលើសហប្រតិបត្តិការយោធា ។ សាឡុត-សរ, អៀង-សារី និងសុន-សេនប្រឆាំងនឹងបញ្ហាការរួម ។ ហ៊ូ-យន់ និងស្វូ-ភីមគាំទ្រសហប្រតិបត្តិការខាងស្ដាំបំផុត ។ នៅក្នុងតំបន់បូព៌ា, រហូតទល់ឆ្នាំ១៩៧៣, សាលាយួនបានរៀបចំបង្កើតកងឯកភាពល្អៗនៃកម្ពុជាប្រជាធិបតេយ្យ (KD) ។ ក្នុងចំណោមពួកនាយទាហានដែលយួនបានរៀបចំបង្កើតឡើងនោះ មានហ៊ុន-សែនម្នាក់ដែរ ។
- ថ្ងៃទី២៧-២៨ មិនា ៖ ខៀវ-សំផន, ហ៊ូ=នឹម និងហ៊ូ-យន់បានប្រកាសជាសាធារណៈ គាំទ្រសីហនុ ។
- ថ្ងៃទី២៩ មិនា ៖ ក្នុងនាមសីហនុ, កងទ័ពយៀកកុង-យៀកណាមខាងជើងបានធ្វើការវាយប្រហារមកលើកងទ័ពរដ្ឋាភិបាល ។ ក្នុងពេលមួយរំពេចសោះ គេឃើញមានវត្តមានកងទ័ពយួនកុម្មុយនិស្តនៅក្នុងខេត្តជាច្រើន ។ ជាការពិតប្រាកដណាស់ ខេត្តស្វាយរៀងស្ថិតនៅក្រោមការត្រួតត្រារបស់ពួកកុម្មុយនិស្តយួន ហើយនិងត្រូវគេរំពឹងគិតថា ស្ថិតនៅក្រោមរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK)ផងដែរ ។
- ថ្ងៃទី២៤-២៥ មេសា ៖ នៅទីក្រុងកង់តុង, មានប្រជុំកំពូលលើកទី២នៃប្រជាជនឥណ្ឌូចិន ដែលមានការចូលរួមពីសីហនុ (ប្រទេសកម្ពុជា), សូផានូវង្ស (ប្រទេសលាវ), ង្វៀង-ហ៊ុយថូ (យៀកកុង) និងផាំ-យ៉ាំងដុង (យួនខាងជើង) ។
- ថ្ងៃទី២៩ មេសា ៖ គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនិស្តយួនសំរាប់វៀតណាមខាងត្បូង បានលើកទៅតាំងទីនៅក្នុងស្រុកព្រែកប្រសប់ (ខេត្តក្រចេះ) ។
- ថ្ងៃទី៣-៤ ឧសភា ៖ សមាជលើកទី១ នៃរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) ធ្វើនៅស្រុកចិន ៖ អនុម័តកម្មវិធីនយោបាយរបស់ខ្លួន ។
- ថ្ងៃទី៥ ឧសភា ៖ ការបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ។ នាថ្ងៃបន្ទាប់ មានការប្រកាសទទួលដោយចិន, យួនខាងជើង, កូរ៉េខាងជើង និងយៀកកុង ។ ចិនកាត់ផ្ដាច់ទំនាក់ទំនងជាមួយរដ្ឋាភិបាលលន់-នល់ ។
- ថ្ងៃទី១៣ ឧសភា ៖ ការផ្លាស់ប្ដូរនៅក្នុងជួររាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ។ ការចូលមកក្នុងរាជរដ្ឋាភិបាលនេះនៃពួកអ្នកតស៊ូក្នុងព្រៃជាច្រើននាក់ ។
- ថ្ងៃទី២០ ឧសភា ៖ កាសែតចិនថ្មីប្រកាសឲ្យដឹងថា ខៀវ-សំផនដឹកនាំការប្រយុទ្ធនៅក្នុងតំបន់បូព៌ា, ហ៊ូ-យន់នៅក្នុងតំបន់ពាយព្យ, ហ៊ូ-នឹមនៅក្នុងតំបន់និរតី ។
- ខែមិថុនា ៖ សាឡុត-សរចេញពីហាណូយចូលតាមខេត្តរតនគីរីរួចហើយបានទៅតាំងទីសេនាធិការ នៅក្នុងស្រុកសន្ទុក (ទិសខាងកើតខេត្តកំពង់ធំ, ដាក់ឈ្មោះថាតំបន់៣១ ទៅតាមពាក្យរបស់កម្ពុជាប្រជាធិបតេយ្យ) ។
- ថ្ងៃទី១០ សីហា ៖ រណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK)ប្រកាសកាន់កាប់ទឹកដីខ្មែរ៥០% ។
- ថ្ងៃទី១៧ សីហា ៖ តុលាការសឹកក្រុងភ្នំពេញ ផ្ដន្ទាទោសដោយអវត្តមានចំពោះម៉ូនិក-សីហនុ ពីបទក្បត់ជាតិ ដោយត្រូវកាត់ឲ្យជាប់គុកអស់មួយជីវិត ។
- ថ្ងៃទី២០ សីហា ៖ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ធ្វើការផ្លាស់ប្ដូរសារជាថ្មី ដោយចំណោញជានិច្ចទៅខាងពួកកុម្មុយនិស្ត ។
- ខែវិច្ឆិកា ៖ ការជួបសន្ទនាគ្នារវាងពួកកុម្មុយនិស្តយួន (ង្វៀង-វ៉ាន់លិញ, ត្រាន់-ណាំទ្រឿង) ជាមួយពួកកុម្មុយនិស្តខ្មែរ (សាឡុត-សរ, នួន-ជា) ។ ការចេញដំណើរពីហាណូយមកកាន់ប្រទេសកម្ពុជា តាមរយៈផ្លូវលំហូ-ជីមិញ នៃពួកទាហានឥស្សរៈរាប់ពាន់នាក់ (នៅក្នុងនោះមានសមាជិកបក្សកុម្មុយនិស្តកម្ពុជាចំនួន៨២២នាក់) ដែលបានទៅហ្វឹកហ្វឺននៅហាណូយតាំងពីឆ្នាំ១៩៥៤ ។ គេហៅពួកខ្មែរទាំងអស់នេះថា ៖ ខ្មែរហាណូយ ឬខ្មែរវៀតមិញ ។
- ថ្ងៃទី៣១ ធ្នូ ៖ យោងតាមរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជានិយាយថា ពួកគេត្រួតត្រាទឹកដីខ្មែរចំនួន៧០% ។

## ★ ឆ្នាំ១៩៧១

- ខែកុម្ភៈ ៖ ការមកដល់ជាលើកទី១នៃពួកខ្មែរហាណូយក្នុងខេត្តក្រចេះ។ ពួកនេះនឹងត្រូវចាកចេញទៅគ្រប់ទិសទីកន្លែងទាំងអស់នៅក្នុងស្រុកខ្មែរ ដោយបក្សកុម្មុយនិស្តកម្ពុជាជាអ្នកបញ្ជូន ។
- ថ្ងៃទី១៩ មិនា ៖ ការធ្វើឲ្យដឹងជាលើកដំបូង អំពីក្បាលអង់តែននៃ

នៃបក្សកុម្មុយនិស្តកម្ពុជា និងកំណើតនៃ «អង្គការ» ។ ( <u>កកន</u> ៖ មានន័យថា «អង្គការ» នេះគឺយួនជាអ្នកបង្កើត ) ។

- ខែកក្កដា ៖ មានការជួបប្រជុំចំនួន២អាទិត្យ នៃក្រុមខ័ណ្ឌបក្សកុម្មុយនិស្តកម្ពុជា (PCK) នៅភ្នំសន្ទុកដើម្បីតែងតាំងគណៈកម្មាធិការមជ្ឈឹមថ្មី ។ គ្មានវត្តមានពួកខ្មែរហាណូយនៅក្នុងពេលនោះទេ ។ អៀង-សារីបានត្រូវគេបញ្ជូនឲ្យទៅប៉េកាំងដើម្បីធានានូវតួនាទីសីហនុ ។ សមាជបានត្រូវកោះហៅ ។ ឈ្មោះស្រុកទាំងប៉ុន្មានដែលស្ថិតនៅក្រោមការត្រួតត្រារបស់បក្សកុម្មុយនិស្តកម្ពុជា ត្រូវប្តូរជាលេខវិញ ។
- ថ្ងៃទី២០ សីហា ៖ ការចាប់ផ្តើមនៃប្រតិបត្តិការចេនឡាទី២ ក្នុងវត្តបំណងដណ្តើមយកវិញនៃខេត្តកំពង់ធំ ពីការត្រួតត្រាកាន់កាប់របស់ពួកកុម្មុយនិស្ត ។ នៅដំណាលពេលប្រតិបត្តិការនេះ, កម្លាំងបក្សកុម្មុយនិស្តកម្ពុជា (PCK) ក្រោមបញ្ជារបស់កែ-ពោក បានវាយយកបានផ្សារបារាយមួយរយៈពេល ។ នេះជាលើកទី១ហើយដែលគេឃើញមានអំពើសម្លាប់នៃទសវត្ស ។ ប្រជាពលរដ្ឋទាំងអស់ដែលកាលពីមុនរស់នៅក្រោមទាហានកុម្មុយនិស្តយួនបានត្រូវសម្លាប់ចោល ។ គំនរឆ្អឹងមួយមានចំនួនជាង១៨០នាក់ បានត្រូវទាហានរដ្ឋាភិបាលប្រទះឃើញ នៅពេលដណ្តើមយកទីផ្សារបារាយនេះមកវិញ ។
- ថ្ងៃទី៣០ កញ្ញា ៖ សមាជលើកទី៣នៃបក្សកុម្មុយនិស្តកម្ពុជា ប្រកាសឲ្យដឹងថា សត្រូវដែលមានគ្រោះថ្នាក់ខ្លាំងជាងគេគឺយួន ។ អត្ថបទមួយមានចំណងជើងថា «សេចក្តីប្រកាសនៃក្រុមបញ្ញវ័ន្តស្នេហាជាតិនៅក្នុងតំបន់រំដោះ» ដែលមានហត្ថលេខាចំនួន៩១ បានត្រូវគេចែកផ្សាយពេញពិភពលោក ។ ពួកខ្មែរហាណូយក៏ចាប់ផ្តើមដកខ្លួនចេញពីមុខនាទីទទួលខុសត្រូវទាំងអស់ ។ សាឡុត-សរជាប់ឆ្នោតជាថ្មីធ្វើជាអគ្គលេខា និងជាប្រធានគណៈកម្មាធិការខាងកងទ័ព ។

## ★ ឆ្នាំ១៩៧២

- ខែមេសា ៖ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា FAPLNK វាយដណ្តើមយកបានផ្សារកំពង់ត្របែក ដែលជាចំណុចយុទ្ធសាស្ត្រយ៉ាងសំខាន់លើផ្លូវទៅកាន់ក្រុងសៃហ្គង ។
- ខែកក្កដា ៖ លើលែងតែតំបន់បូពាំចេញ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បក្សកុម្មុយនិស្តកម្ពុជា, សូ-ភឹមមិនស្តាប់បញ្ជាទេ, ប្រជាជនស្ថិតនៅក្រោមការត្រួតត្រារបស់បក្សកុម្មុយនិស្តកម្ពុជា បន្តិចម្តងៗបានត្រូវគេបង្ខំឲ្យស្លៀកពាក់ខ្មៅដូចអ្នកស្រែ

## ★ ឆ្នាំ១៩៧៣

- ថ្ងៃទី១ មករា ៖ លន់-នល់បដិសេធគ្រប់ការចរចាជាមួយសីហនុ
- ថ្ងៃទី១ មករា ៖ ការលាឈប់ពីតំណែងនៃកែវ-ចិន្តា, ប៉ែន-សុវណ្ណ និងក្រុមខ័ណ្ឌដទៃទៀត ដែលធ្វើការក្រោមបង្គាប់របស់អៀង-ធិរិទ្ធ នៅឯស្ថានិយប៉ុស្តិ៍វិទ្យុបក្សកុម្មុយនិស្តកម្ពុជា ដែលគេដំឡើងនៅហាណូយ ។ ពួកគេទៅចូលរួមជាមួយជា-សុទ្ធ ដើម្បីចង់បង្កបង្កើតគណបក្សថ្មីមួយទៀត តែត្រូវបានយួនពន្យល់ឲ្យបោះបង់ចោលគំនិតនេះ ។
- ថ្ងៃទី២១-២៦ មករា ៖ ការជួបសន្ទនាគ្នារវាងបក្សកុម្មុយនិស្តកម្ពុជាជាមួយបក្សកុម្មុយនិស្តយួន ។ ខាងយួនបានប្រាប់ទៅពួកកុម្មុយនិស្តខ្មែរឲ្យបន្តទទួលស្គាល់កិច្ចព្រមព្រៀងប៉ារីស។ បក្សកុម្មុយនិស្តខ្មែរច្រានចោលការទាមទាររបស់យួនចង់ទម្លាយកិច្ចចរចា ។ យួនព្យួរទុកឈប់បញ្ជូនអាវុធចិន ទៅឲ្យកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK) ។
- ថ្ងៃទី២៧ មករា ៖ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសអំពីស្រុកយួន ។ កងទ័ពយួនខាងជើងបានត្រូវដកចេញជាបន្តបន្ទាប់ពីក្នុងទឹកដីខ្មែរ ។ បីកងពលធំ ដែលមានវត្តមានរហូតដល់ចុងឆ្នាំ១៩៧២ ក៏បានចូលទៅក្នុងស្រុកយួន, កងពលធំទី៤បានចាប់វាយនៅក្នុងតំបន់ព្រំដែនខេត្តកំពង់ចាម ។ នៅក្នុងតំបន់ខ្លះត្រួតត្រាដោយពួកប៉ុល-ពតនៃបក្សកុម្មុយនិស្តកម្ពុជា (តំបន់លេខ២៥ ក្រោមបញ្ជារបស់តាម៉ុក), ការដកកងទ័ពយួនកុម្មុយនិស្ត បានធ្វើយ៉ាងប្រញាប់ប្រញាល់ នៅក្រោមគំនាបសង្កត់នៃសម្ព័ន្ធមិត្តខ្មែរជាដៃគូចាស់របស់ខ្លួន ។
- ពាក់កណ្តាលខែកុម្ភៈ ៖ សីហនុទៅដល់ហាណូយ ។ តាមរយៈផ្លូវលំហូ-ជីមិញ សីហនុមានបំណងទៅធ្វើទស្សនកិច្ចតំបន់ត្រួតត្រាដោយពួករណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) ។ ( <u>កកន</u> សូមមើលរូបថតខាងដើម ។ ស្តេចសីហនុបានទៅស្រុកខ្មែរ តាមរយៈយួនហាណូយ នៅក្រោយពេលពួកខ្មែរក្រហមបំបែកខ្លួនចេញពីយួន ។ ចំណុចនេះបញ្ជាក់ឲ្យឃើញថា ស្តេចសីហនុបានត្រូវយួនប្រើឲ្យទៅនិយាយសំរួលគ្នាជាមួយខ្មែរក្រហម ) ។
- ថ្ងៃទី២៣ មិនា ៖ សីហនុទៅដល់ភ្នំគូលែន ជាមួយម៉ូនិក, ហ៊ូ-នឹម, ហ៊ូ-យន់, ខៀវ-សំផន, សុន-សេន និងសាឡុត-សរ ។ មានការជួបជុំគ្នាធ្វើបុណ្យយ៉ាងធំមួយ ដើម្បីប្រារព្ធខួបឆ្នាំទី៣នៃកំណើតរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) ។
- ថ្ងៃទី៩ មេសា ៖ សីហនុវិលត្រឡប់ទៅដល់ហាណូយ ។
- ថ្ងៃទី១១ មេសា ៖ ការវិលត្រឡប់របស់សីហនុទៅប៉េកាំង ។
- ថ្ងៃទី២០ ឧសភា ៖ ការចាប់ផ្តើមសមូហកម្មកសិកម្មនៅក្នុងតំបន់រំដោះត្រួតត្រាដោយរណៈសិរ្សបង្រួបបង្រួមជាតិកម្ពុជា នឹងដែលកាន់កាប់កាន់តែខ្លាំងឡើងៗដោយបក្សកុម្មុយនិស្តកម្ពុជា ។ ការបង្កើតច្បាប់តម្រូវឲ្យរស់នៅជារបៀបសហករណ៍ ។ ការបំបាត់ចោលលែងឲ្យប្រើលុយ ។ ការធ្វើឲ្យឃ្លាតគ្នា រួចបន្ទាប់មកបំបាត់ចោលជាបន្តបន្ទាប់នៃពួកសីហនុនិយម និងពួកខ្មែរហាណូយ ។ ការចាប់ផ្តើមបំបាត់រូបភាពដូចវិធីរដ្ឋាភិបាល ចំពោះប្រជាជនរស់នៅក្រោមការកាន់កាប់របស់បក្សកុម្មុយនិស្តកម្ពុជា ។ មានការប៉ះទង្គិចគ្នាជាមួយកងទ័ពយួនកាន់តែច្រើនឡើងនៅក្នុងស្រុកខ្មែរ ។ ជាទូទៅ, ពួកយោធានៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK) បានក្លាយទៅ «យោធាខ្មែរក្រហម»របស់ប៉ុល-ពត ។
- ថ្ងៃទី១២ សីហា ៖ ក្នុងសម្ភាសន៍ជាមួយ Oriana Fallaci, សីហនុប្រកាសថា «ពួកខ្មែរក្រហមលែងត្រូវការខ្ញុំទៀតហើយ... ពួកគេខ្ទាក់ខ្ញុំចោលដូចគ្រាប់ឈើរី» (The New York Times Magazine)
- ថ្ងៃទី១០ តុលា ៖ សហភាពសូវៀតជាប្រទេសទី៦២ ទទួលស្គាល់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ។
- ថ្ងៃទី៩ វិច្ឆិកា ៖ ការបញ្ជូនក្រសួង នៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាទាំងអស់ ចូលទៅក្នុងស្រុកខ្មែរ ។
- ខែវិច្ឆិកា ៖ ការប៉ះទង្គិចគ្នារវាងកងទ័ពសីហនុនិយម ដែលរួមសហការដោយពួកកុម្មុយនិស្តយួន ជាមួយកងទ័ពដែលស្តាប់តាមបញ្ជារបស់ប៉ុល-ពត បានត្រូវបញ្ចប់ ។
- ខែធ្នូ ៖ ការបោះពុម្ពនៅភ្នំពេញ, សៀវភៅរបស់ចាងហ្វាងសាលាបឋមសិក្សា អ៊ិត-សារិនឈ្មោះ «ស្រណោះព្រលឹងខ្មែរ» កាលគា

ត់រស់នៅ៩ខែក្នុងតំបន់កុម្មុយនិស្ត។ សៀវភៅបើកបង្ហាញអំពីការអនុវត្តន៍នៃបក្សកុម្មុយនិស្តកម្ពុជា នៅក្នុងទឹកដីក្រោមការកាន់កាប់របស់ខ្លួន ។

- ថ្ងៃទី៣ ធ្នូ ៖ ការផ្លាស់ប្តូរលើកទីបួន នៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ។ សមាសភាពនៃរាជរដ្ឋាភិបាលនេះ គឺបានធ្វើការរហូតទៅទល់ខែមេសា ឆ្នាំ១៩៧៦ ។

**★ ឆ្នាំ១៩៧៤**

- ថ្ងៃទី១៨ មិនា ៖ ក្រោមការប្រយុទ្ធគ្នាខ្លាំងក្លា, កងទ័ពប្រជាជនរំដោះជាតិកម្ពុជា នៅក្រោមបញ្ជាការរបស់កែ-ពោកនិងតាម៉ុក បានកាន់កាប់ឧដុង្គ ។ ក្រុងត្រូវបានបោសសំអាត ។ ប្រជាពលរដ្ឋចំនួន២០,០០០នាក់ បានត្រូវគេដឹកជញ្ជូនទៅកាន់ទិសផ្សេងៗ, ពួកគ្រូបង្រៀន, ពួកអ្នករដ្ឋការ ហើយនឹងទាហានសាធារណរដ្ឋត្រូវគេប្រហារជីវិត ។
- ថ្ងៃទី៩ កក្កដា ៖ កងយោធពលខេមរជាតិ បានវាយដណ្តើមយកឧដុង្គមកវិញ ។ ក្រោមការជួយប្រឹងប្រែងរបស់ John Gunther Dean រដ្ឋទូតអាមេរិកាំងថ្មីប្រចាំប្រទេសកម្ពុជា, លន់-នល់ចង់ស្នើធ្វើការចរចាជាមួយក្រុមខ្មែរម្ខាងទៀត ដោយគ្មានលក្ខខ័ណ្ឌ ។ សីហានុបានច្រានចោលសំណូមពរនេះ ហើយប្រកាសថា ៖ «ខ្ញុំនឹងមិនចូលក្រុងភ្នំពេញដាច់ខាត បើប្រជាជនទាំងអស់មិនកំទេចចោលទេ» ។ ( កកន ៖ សំដីរបស់ស្តេចសីហានុនេះសាហាវខ្លាំងណាស់ គឺកំពុងស្រេកឈាមប្រជាពលរដ្ឋខ្មែរឡើងញ័រខ្លួន ) ។

**★ ឆ្នាំ១៩៧៥**

- ថ្ងៃទី១ មករា ៖ ការចាប់ផ្តើមវាយយកក្រុងភ្នំពេញ នៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK) ។
- ថ្ងៃទី២៤-២៥ កុម្ភ: ៖ រណ:សិរ្សបង្រួបបង្រួមជាតិកម្ពុជានិងបក្សកុម្មុយនិស្តកម្ពុជា (FUNK - PCK) ចេញផ្សាយនូវបញ្ជី «ជនក្បត់៧នាក់»ត្រូវប្រហារជីវិតគឺ ៖ លន់-នល់, សិរិមត:, អ៊ិន-តាំ, ចេងហេង, សុស្តែន-ហ្វែរណង់ដែស, លន់-ណុន និងឡុង-បូរ៉េត។
- ថ្ងៃទី៤ មេសា ៖ នៅក្នុងពេលប្រជុំមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ហ៊ូ-យន់, ណៃ-សារ៉ាន់ និង ឈូក ប្រឆាំងគំរោងការជម្លៀសប្រជាជនចេញពីទីក្រុង និងការលប់បំបាត់លុយចោល ។
- ថ្ងៃទី១៧ មេសា ៖ ខ្មែរក្រហមកាន់កាប់បានទីក្រុងភ្នំពេញ ។
- ថ្ងៃទី២៤ មេសា ៖ សាឡុត-សរចូលភ្នំពេញ បន្ទាប់ពីចាកចេញកាលពីឆ្នាំ១៩៦៣ ។
- ថ្ងៃទី២៥-២៧ មេសា ៖ សមាជជាតិពិសេស ជួបជុំគណ:ប្រតិភូពិសេសចំនួន៣៣១រូប ៖ ១២៥រូបតំណាងអង្គការ, ១១២រូបតំណាងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK), ព្រះសង្ឃ២០អង្គ, ៤១រូបតំណាងរណ:សិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK) និង១៣រូបជាសមាជិករាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ។ សមាជប្រកាសស្រុកខ្មែរក្លាយទៅជា «កម្ពុជាប្រជាធិបតេយ្យ», ស្តេចសីហានុជាប្រមុខរដ្ឋ ហើយនិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ត្រូវដឹកលទុកជា រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ។
- ថ្ងៃទី១៩ ឧសភា ៖ សីហានុចេញទៅក្រុងព្យុងយ៉ាង ។
- ថ្ងៃទី២០-២៦ ឧសភា ៖ ក្របខ័ណ្ឌនយោបាយនិងយោធាទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ បានប្រជុំគ្នានៅក្នុងមណ្ឌលកីឡាដ្ឋានក្រុងភ្នំពេញ ។ ទិសដៅនយោបាយធំៗនៃរបបថ្មី ដែលចែកចាយដោយសាឡុត-សរនិងនួន-ជាមានប្រាំបីចំណុចគឺ ៖ ១-ជម្លៀសជាអចិន្ត្រៃយ៍ប្រជាជនទីក្រុងទាំងអស់ រួចបែងចែកជាពីរប្រភេទ ប្រជាជនថ្មីនិងប្រជាជនចាស់ នៅតាមតំបន់នានា, ២-លប់បំបាត់ចោលសេដ្ឋកិច្ចទីផ្សារគ្រប់បែប, ៣-លប់បំបាត់ចោលលុយគ្រប់ធុន, ៤-ផ្សឹកព្រះសង្ឃឲ្យទៅធ្វើស្រែចំការ, ៥-ប្រហារជីវិតក្របខ័ណ្ឌទាំងអស់នៃរបបសាធារណរដ្ឋ, ៦-បង្កើតសហករណ៍ទូទាំងប្រទេស, ៧-បណ្តេញជនជាតិយួនទាំងអស់ចេញពីស្រុក, ៨-រាយកងទ័ពនៅតាមបណ្តោយព្រំដែន ជាពិសេសព្រំដែនយួន ។ អនាគតមេដឹកនាំ៣រូបនៃសាធារណរដ្ឋប្រជាមានិតុកម្ពុជា ម៉ាត់-លី, ជា-ស៊ីម និងហេង-សំរិន ក៏បានចូលរួមនៅក្នុងប្រជុំនោះដែរ ។
- ថ្ងៃទី២ មិថុនា ៖ ការជួបសន្ទនាគ្នារវាងសាឡុត-សរនិងឡៀង-វ៉ាន់លិញនៅហាណូយ ដើម្បីបង្កើតជាគណ:កម្មាធិការចំរុះព្រំដែនមួយ ។
- ថ្ងៃទី២១ មិថុនា ៖ នៅប៉េកាំង មានការជួបគ្នារវាងសាឡុត-សរនិងម៉ៅ-សេទុង ។
- ថ្ងៃទី១៨ កក្កដា ៖ សារិន-ឆាក និងជួន-ប្រាសិទ្ធិទៅក្រុងព្យុងយ៉ាង ដើម្បីសុំយាងសីហានុចូលក្រុងភ្នំពេញ ។ សីហានុប្រកែក ។
- ខែសីហា ៖ ហ៊ូ-យុនមិនយល់ស្រប ការវាយប្រហារប្រឆាំងយួន ហើយសុំលាលែងពីតំណែង ។ គាត់ក៏បាត់ខ្លួន ។
- ថ្ងៃទី៥ សីហា ៖ ទស្សនកិច្ចផ្លូវការនៃខៀវ-សំផននិងអៀង-សារីនៅប៉េកាំង ។
- ថ្ងៃទី១៨ សីហា ៖ ប៉ែន-នុតនិងខៀវ-សំផនទៅប៉េកាំង ។ ចិនសន្យាជំនួយសន្ធឹកសន្ធាប់ដល់របបថ្មី ។
- ថ្ងៃទី១៩ សីហា ៖ ប៉ែន-នុតនិងខៀវ-សំផនទៅកាន់ទីក្រុងព្យុងយ៉ាង ហើយបានស្នើផ្តល់សីហានុនូវតំណែងប្រមុខរដ្ឋមួយជីវិត។ សីហានុយល់ព្រម ។
- ថ្ងៃទី២ កញ្ញា ៖ សីហានុទៅដល់ហាណូយ ។ ( កកន ៖ មុននឹងធ្វើអ្វីឬទទួលយកអ្វី សីហានុត្រូវទៅសួរយោបល់ពីយួនសិន ) ។
- ថ្ងៃទី៩ កញ្ញា ៖ សីហានុចូលទៅដល់ភ្នំពេញ ធ្វើជាអធិបតីក្នុងកិច្ចប្រជុំមួយនៃក្រុមគណ:រដ្ឋមន្ត្រី ។ ការសុំយកធាតុម្តាយទៅបញ្ចុះអង្គរវត្តបានត្រូវបដិសេធ ។
- ថ្ងៃទី២០ កញ្ញា ៖ ជនភៀសខ្លួនបានទៅដល់ក្រុងបាងកក និយាយប្រាប់ប្រធានអ.ស.ប. ហើយស្តេចសីហានុ នៅក្នុងកំណត់ហេតុមួយ បានសរសេររៀបរាប់អំពីអំពើឃោរឃៅនៅក្នុងស្រុកខ្មែរចាប់ពីថ្ងៃទី១៧មេសាមក ។ នៅក្នុងថ្ងៃជាមួយគ្នានេះ សីហានុបានចាកចេញទៅញូវយ៉ក ដើម្បីចូលរួមប្រជុំអ.ស.ប. ។ បន្ទាប់ទ្រង់បានធ្វើទស្សនកិច្ចជាង១០ប្រទេស មុនពេលត្រឡប់ទៅព្យុងយ៉ាង។ ( កកន ៖ សូមបញ្ជាក់ថា សីហានុបានដឹងពីអំពើឃោរឃៅរួចទៅហើយ នៅមុនពេលចេញទៅធ្វើជា<តំណាងខ្មែរក្រហម> នៅក្នុងមហាសន្និបាតអ.ស.ប. ។ សួរថាតើហេតុអ្វីបានជាសីហានុមិនធ្វើតវ៉ាប្រឆាំងរឿងនេះ ? ។ គ្មាននរណាដឹងទេ ។ តែពួកខ្មែរក្រហមយល់ក្រយៅសីហានុ គឺបណ្តោយឲ្យសីហានុសប្បាយភ្លើតភ្លើននឹងតំណែងជាប្រមុខរដ្ឋថ្មីរបស់ខ្លួនហោះហើរទៅបង្ហាញមុខនៅស្ទើរគ្រប់ប្រទេសប្លុកកុម្មុយនិស្ត ដើម្បីអួតអំពីជ័យជំនះរបស់ខ្លួនលើចក្រពត្តិអាមេរិកាំងនិងពួកបរិវារ តាមរបៀបស្តេចស៊ីជោរ ) ។
- ថ្ងៃទី៣១ ធ្នូ ៖ សីហានុវិលចូលភ្នំពេញវិញ ។០៚